**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economic Science**


## សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **លោក ស ច័ន្ទបូរី** សាស្ត្រាចារ្យណែនាំ

**កញ្ញា ម៉ែត ឆព័ន្ធតារ៉ា** លោកមេធាវី **ហេង ម៉ូរ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១ ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **ស ច័ន្ទបូរី** នាងខ្ញុំ **ខៃ៉ត ឆព័ន្ធតារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ក្រុម L4A1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមធ្វើគារវកិច្ច និង កតញ្ញូតាធម៌ចំពោះ

- លោកឪពុកអ្នកម្ដាយដែលមានគុណយ៉ាងធំធេងមិនអាចកាត់ថ្លៃបានចំពោះរូបកូន ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូនដោយព្រហ្មវិហារធម៌ និងបាន បញ្ជូនកូនឲ្យទៅ សាលារៀនដើម្បីសិក្សារៀនសូត្រ ក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅប្រកបដោយកិត្តិយសនិង សេចក្ដីថ្លៃថ្នូរ ។

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់។

ជាពិសេសលោកសាស្ត្រាចារ្យ **ហេង មូរ៉ា** ដែលបានបង្ហាត់បង្រៀនទូន្មានប្រៀនប្រដៅ បង្ហាញទិសដៅ និងផ្ដល់ ជាអនុសាសន៍ល្អៗ ពន្យល់ណែនាំយើងខ្ញុំ អស់ពីកម្លាំងកាយចិត្តអស់ពីសមត្ថភាព មិនគិតអំពីការនឿយហត់ក្នុង ការអប់រំគ្រប់ បែបយ៉ាងមិនថាចំណេះដឹងនិងសីលធម៌។ គុណូបការៈដ៏ថ្លៃថ្លា ទាំងនេះ ធ្វើឲ្យ យើងខ្ញុំដឹងគុណ និង ចងចាំជានិច្ចមិន អាចបំភ្លេចបាននិងសូមប្រសិទ្ធ ពរជ័យ សូមលោក សាស្ត្រាចារ្យបានជួបប្រទះ តែគុណបុណ្យព្រះរតនត្រ័យ ដែលជាវត្ថុ ស័ក្តសិទ្ធិ ក្នុងលោកមាន ពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលា ព្រមទាំង ពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ដោយក្តីគោរព ដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអំពីយើងខ្ញុំ ។

## **អារម្ភកថា**

ពីមួយថ្ងៃទៅមួយថ្ងៃ បញ្ហាតែងតែកើតមានឡើងទៅលើមនុស្សគ្រប់រូប មិនត្រឹមតែប៉ុណ្ណោះទំនាស់ឡើងទៅតុលាការក៏តែងកើតមានឡើងផងដែរ។

ក្នុងនាមខ្ញុំ ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្កើតកម្រងកិច្ចការស្រាវជ្រាវនេះឡើង ក្នុងគោលបំណងចែករំលែកនូវចំណេះដឹង ដែលបានសិក្សា កន្លងរួចមកហើយ ជាពិសេសគឺដើម្បីបង្ហាញពីសមត្ថភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹង ប្រធានបទ " ការចាត់ចែងរក្សាការពារលើអចលនវត្ថុ " ជាផ្នែកមួយនៃមុខវិជ្ជា នីតិវិធីរដ្ឋប្បវេណី ដែលបានណែនាំ និងការជំរុញលើកទឹកចិត្តផ្ទាល់ពីសំណាក់ លោកសាស្ត្រាចារ្យ **ហេង មូរ៉ា** សម្រាប់ជាកិច្ចការស្រាវជ្រាវ។

តាមរយៈប្រធានបទដ៏មានសារៈសំខាន់ខាងលើ យើងខ្ញុំសង្ឃឹមថា កម្រងអត្ថបទស្រាវជ្រាវ មួយនេះពិតជាអាចផ្តល់ចំណេះដឹងមួយផ្នែកដល់បណ្តាអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ដែលចង់ដឹង ឬចង់សិក្សាស៊ីជម្រៅ និងជាស្ពានចម្លងសម្រាប់បណ្តាអ្នកសិក្សាស្រាវជ្រាវ និងសិស្ស និស្សិតជំនាន់ក្រោយបន្តការសិក្សាស្រាវជ្រាវបន្ថែម។

ជាទីបញ្ចប់យើងខ្ញុំ សូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើង ដោយអចេតនាតាមរយៈ កំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមស្របក៏ដូចជាកង្វះខាតអត្ថន័យក្តី។ ជាពិសេសយើងខ្ញុំសង្ឃឹមថា នឹងទទួលបានការយោគយល់ អធ្យាស្រ័យ ហើយក៏រង់ចាំទទួលរាល់ការកែលម្អពីសំណាក់ សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយ។

ថ្ងៃ.........................ខែ........... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ភ្នំពេញ, ថ្ងៃទី......... ខែ....... ឆ្នាំ២០២១

និស្សិតឈ្មោះ

**ស ច័ន្ទបូរី** **ខៃ៊ត ឆព័ន្ធតារ៉ា**

## មាតិកា ទំព័រ

**សេចក្ដីផ្ដើម**......................................................................................................................**១**

**ជំពូកទី១**

**សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារ**

**១.១ និយមន័យនៃការចាត់ចែងរក្សាការពារ**.....................................................................៣

១.១.១ គោលបំណងនៃការចាត់ចែងរក្សាការពារ.....................................................................៤

១.១.២ វិសាលភាពនៃការចាត់ចែងរក្សាការពារ.....................................................................៤

**១.២ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី**..........................................៥

១.២.១ ការរឹបអូសជាបណ្ដោះអាសន្ន.............................................................................**៥**

១.២.២ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ.....................................**៦**

១.២.៣ ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន..................................**៧**

**១.៣ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ**...............................................................៧

១.៣.១ លក្ខណៈបណ្ដោះអាសន្ន....................................................................................៨

១.៣.២ លក្ខណៈបន្ទាន់បង្ហំ..........................................................................................៨

១.៣.៣ លក្ខណៈបន្ទាប់បន្សំ..........................................................................................៨

១.៣.៤ លក្ខណៈសម្ងាត់...............................................................................................៨

**១.៤ សមត្ថកិច្ចរបស់តុលាការចំពោះការចាត់ចែងរក្សាការពារ**...............................................៨

១.៤.១ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី.....................................................៨

១.៤.២.សាលាដំបូងមានសមត្ថកិច្ចលើវត្ថុដែលនឹងត្រូវរឹបអូស ឬ កម្មវត្ថុនៃវិវាទ..............................**៩**

**ជំពូកទី២**

**ការអនុវត្តដីកាសម្រេចរក្សាការពារ**

**២.១ ដីកាសម្រេចរក្សាការពារ**....................................................................................**១០**

២.១.១ ការដាក់ពាក្យសុំចេញដីការក្សាការពារ...................................................................**១០**

២.១.១.១ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ.................................................................**១០**

**ក** ឈ្មោះ និង អាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់។..........................................................................................................**១០**

ខ ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ........ ១១
គ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ........ ១១
ឃ ភាពចាំបាច់នៃការរក្សាការពារ ........ ១១
ង ភស្តុតាងតាមហេតុនីមួយៗ។ ........ ១១
២.១.២ សោហ៊ុយ ........ ១២
២.១.៣ ប្រភេទនៃដីកាសម្រេចរក្សាការពារ ........ ១៣
២.១.៣.១ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរក្សាការពារ ........ ១៣
២.១.៤ លក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ ........ ១៤
២.១.៤.១ សិទ្ធិដែលត្រូវបានរក្សាការពារ ........ ១៤
២.១.៤.២ ភាពចាំបាច់នៃការរក្សាការពារ ........ ១៥
**២.២ ប្រាតិភោគ** ........ ១៦
២.២.១ គោលបំណងនៃប្រាតិភោគ ........ ១៦
២.២.២ ចំនួននៃប្រាតិភោគ ........ ១៧
២.២.៣ វិធីនៃការដាក់ប្រាតិភោគ ........ ១៧
**២.៣ ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន** ........ ១៨
២.៣.១ គោលបំណងនៃប្រាក់រំដោះ ........ ១៨
២.៣.២ ចំនួននៃប្រាក់រំដោះ ........ ១៨
២.៣.៣ វិធីនៃការដាក់ប្រាក់រំដោះ ........ ១៩
**២.៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ** ........ ១៩
២.៤.១ ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ ........ ១៩
២.៤.២ ដីកាសម្រេចលើកចោលពាក្យសុំ ........ ១៩
**២.៥ ការអនុវត្តការរក្សាការពារចំពោះអចលនវត្ថុ** ........ ១៩
២.៥.១ លក្ខខណ្ឌក្នុងការអនុវត្ត ........ ១៩
២.៥.២ ស្ថាប័នមានសមត្ថកិច្ច ........ ២០
២.៥.៣ ការរឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុ ........ ២១

## ជំពូកទី ៣

## ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ

**៣.១ នីតិវិធីនៃការតវ៉ានូវសេចក្តីសម្រេចចាត់ចែងរក្សាការពារ**............................ ២៣
៣.១.១ ការដាក់ពាក្យសុំតវ៉ា ........................................................................ ២៣
៣.១.២ ការទាញហេតុផលផ្ទាល់មាត់.................................................................. ២៤
៣.១.៣ ដីកាសម្រេចការសុំតវ៉ាលើដីកាសម្រេចចាត់ចែងរក្សាការពារ.......................... ២៤
**៣.២ ការលុបចោលដីកាសម្រេចរក្សាការពារ**.................................................. ២៤
៣.២.១ មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ ....................................... ២៥
៣.២.២ ការទាញហេតុផលផ្ទាល់មាត់.................................................................. ២៧
៣.២.៣ ផ្អាកបណ្តោះអាសន្ន ............................................................................ ២៧
៣.២.៤ អានុភាពនៃដីកាដែលសម្រេចលុបចោលដីកាសម្រេច ....................................... ២៨
**៣.៣ ការបណ្តឹងជំទាស់**............................................................................ ២៨
៣.៣.១ មូលហេតុនៃបណ្តឹងជំទាស់ .................................................................... ២៨
៣.៣.២ ការទាញហេតុផលដោយផ្ទាល់មាត់ ........................................................... ២៨
៣.៣.៣ ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់.................................................. ២៩
៣.៣.៤ អំឡុងពេលនៃបណ្តឹងជំទាស់.................................................................. ២៩
**សេចក្តីសន្និដ្ឋាន**.................................................................................. ៣០
**អនុសាសន៍**........................................................................................ ៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ពេលបច្ចុប្បន្ននេះ មនុស្សគ្រប់រូបតែងតែមានការប្រាស្រ័យទាក់ទងរវាងគ្នានិងគ្នាជាចាំបាច់ ហើយគ្មានបុគ្គលណាអាចរស់នៅក្នុងសង្គមនេះដោយគ្មានការប្រាស្រ័យទាក់ទងនោះឡើយ។ នេះជាដើមហេតុ ដែលធ្វើអោយមនុស្សម្នាក់ៗ មានកាតព្វកិច្ចរវាងគ្នានិងគ្នាទៅវិញទៅមកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងការបំពេញកាតព្វកិច្ចបុគ្គលជាច្រើន បានប្រតិបត្តិតាមកិច្ចសន្យាដោយគោរពនូវសិទ្ធ និងផលប្រយោជន៍របស់ភាគីម្ខាងទៀត ហើយអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ដោយភាពត្រឹមត្រូវ សុចរិតទៀងត្រង់ ។ រីឯបុគ្គលមួយចំនួនតូច បានបំពានកិច្ចសន្យា និងមិនបានបំពេញនូវកាតព្វកិច្ចជាមួយភាគីមួយផ្សេងទៀត។ ជាពិសេស នៅក្នុងកិច្ចសន្យាពាក់ព័ន្ធជាមួយអចលនវត្ថុ បុគ្គលដែលទទួលនូវការរំលោភបំពានសិទ្ធ ឬក៏ផលប្រយោជន៍របស់ខ្លួនពីអ្នកដទៃដោយខុសច្បាប់នោះ អាចប្រើប្រាស់នូវសិទ្ធតាមផ្លូវច្បាប់ដើម្បីការយុត្តិធម៌ ឬការទាមទារនូវផលប្រយោជន៍របស់ខ្លួនវិញបាន។ ដូច្នេះក្នុងករណី បុគ្គលដែលត្រូវគេបំពានមានការបារម្ភថា មិនអាចអះអាងជាមួយជនដែលបំពានមកលើខ្លួនដោយខុសច្បាប់ និងដើម្បីរក្សាស្ថានភាពនូវកម្មវត្ថុនៃវិវាទ ជាពិសេសករណីអចលនវត្ថុ (ដី ឬ ផ្ទះ) ដើម្បីជៀសវាងនូវហានិភ័យដែលអាចកើតមានដូចជា ឈូស ឆាយ លក់ដូរ ជួល បញ្ចាំ ប្រទានកម្ម ធ្វើបណ្តាំមរតក ការចាត់ចែងរក្សាការពារតាមរយៈផ្លូវតុលាការដែលរួមមាន ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ជានីតិវិធីដ៏ល្អបំផុត ដែលអាចជួយការពារផលប្រយោជន៍ស្របច្បាប់ និង ថែរក្សាស្ថានភាពដើម ដោយប្រើប្រាស់អំណាចរដ្ឋ រួមទាំងជួយធ្វើអន្តរាគមន៍ដើម្បីការពារ នូវការរំលោភបំពានសិទ្ធ និងផលប្រយោជន៍ជូនបុគ្គលដែលរងគ្រោះដោយយុត្តិធម៌ និង ស្របច្បាប់ ។ ជាទូទៅ ម្ចាស់បំណុលតែងតែជ្រើសរើសនីតិវិធីនេះ ដោយស្នើសុំតុលាការចេញដីកាសម្រេចចាត់ចែងរក្សាការពារ ប្រសិនបើនៅរង់ចាំការអនុវត្តតាមលំដាប់លំដោយ ដែលវានាំឱ្យមានភាពយឺតយ៉ាវក្នុងការការពារសិទ្ធ និងផលប្រយោជន៍របស់ខ្លួនឱ្យទាន់ពេលវេលាមុនពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

តើការចាត់ចែងរក្សាការពារមានអត្ថន័យយ៉ាងដូចម្តេច ? តើអ្វីទៅជាដីកាសម្រេចរក្សាការពារ និង គេអនុវត្តការចាត់ចែងរក្សាការពារយ៉ាងដូចម្តេច? តើយើងអាចធ្វើបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារបានដែរឬទេ ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ ខ្ញុំបាទ/នាងខ្ញុំមានគោលបំណង ចែករំលែកចំណេះដឹង ដែលបានសិក្សារៀនសូត្រ និងដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើ នីតិវិធីចាត់ចែងរក្សាការពារលើអចលនវត្ថុ និងទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវ ព្រមទាំងនិស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់ពីប្រធានបទនេះ ។

## ៤.ទំហំនៃការស្រាវជ្រាវ

នៅក្នុងអត្ថបទនេះ ផ្តោតទៅលើច្បាប់ជាទូលាយ អំពីទ្រឹស្តីដែលបានចែងនៅក្នុង ក្រមនីតិវិធីរដ្ឋប្បវេណី ទាក់ទងការចាត់ចែងរក្សាការពារ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត ។

## ៥.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ ការចាត់ចែងរក្សាការពារលើអចលនវត្ថុនេះ ត្រូវបានធ្វើការបែងចែកជាបួនជំពូករួមមាន៖

ជំពូកទី១ សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារ

ជំពូកទី២ ការអនុវត្តដីកាសម្រេចរក្សាការពារ

ជំពូកទី៣ ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ

និងត្រូវបានបកស្រាយនៅខាងក្រោម ជាបន្តបន្ទាប់ដូចតទៅ ៖

# ជំពូកទី១

# សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារ

## ១.១ និយមន័យនៃការចាត់ចែងរក្សាការពារ

### ១.១.១ គោលបំណងនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងរក្សាការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[1]។ មិនត្រឹមតែជាច្បាប់ទម្រង់ប៉ុណ្ណោះទេ សូម្បីតែច្បាប់សារធាតុក៏បានជួយធ្វើការអន្តរាគមន៍ផងដែរ ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលចង់យកទ្រព្យសម្បត្តិដែលមាននោះ គេចវេសពីការអនុវត្តដោយបង្ខំដោយការឃុបឃិតគ្នាជាមួយនិងតតិយជន ក៏ត្រូវបានចាត់ទុកជាមោឃៈដែរ។ ផ្ទុយទៅវិញ បើតតិយជននោះ ជាជនសុចរិតម្ចាស់បំណុលក៏មិនអាចអះអាងចំពោះតតិយជននោះបានដែរ[2]។ ត្រង់ចំណុចនេះហើយ ដែលធ្វើម្ចាស់បំណុលជ្រើសរើសយកនីតិវិធីចាត់ចែងរក្សាការពារ ដែលជាមធ្យោបាយដែលល្អមួយដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន។ នៅពេលដែលមានបណ្ដឹងអង្គសេចក្ដី ដែលត្រូវបានចាត់ការនោះគឺ ត្រូវចំណាយពេលវេលាមួយវែងដែលមិនអាចកំណត់បាន ដូច្នេះនៅអំឡុងពេលនៃនីតិវិធីអង្គសេចក្ដីនេះ ពេលខ្លះម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុល ដែលលាក់ទុកទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈ ការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំ ប្រទានកម្មជាដើម។ ហេតុនេះហើយ នាំឱ្យម្ចាស់បំណុលមានការលំបាកក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននៅពេលដែលម្ចាស់បំណុលឈ្នះក្ដី ដោយសារតែមើលឃើញបែបនេះហើយទើបបានជា ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦ មានគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលរហូតដល់នីតិវិធីបណ្ដឹងដល់ទីបញ្ចប់។ ហើយមិនថាម្ចាស់បំណុលនោះ ជាអ្នកណាមកពីណាក៏ដោយ ឬទោះម្ចាស់ជាជនជាតិអ្វីក៏ដោយ ឱ្យតែម្ចាស់បំណុលមានសមត្ថភាពគ្រប់គ្រាន់ស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាម្ចាស់បំណុល គ្មានសមត្ថភាពស្របតាមច្បាប់នៃប្រទេសរបស់ខ្លួនក៏ដោយ ក៏ម្ចាស់បំណុលអាចដាក់សុំឱ្យតុលាការធ្វើការចាត់ចែងរក្សាការពារបានដែរ។

---

[1] មាត្រា៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[2] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

ការចាត់ចែងរក្សាការពារ នេះផងដែរបានចែកជា ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជា បណ្តោះអាសន្ន។ ការចាត់ចែងជាបណ្តោះអាសន្នចែកជា ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[3] ។ ការរឹបអូសជាបណ្តោះអាសន្នធ្វើឡើងក្នុងករណី សិទ្ធិដែលត្រូវបានរក្សាការពារគឺជាសិទ្ធិទាមទារឱ្យសងជាប្រាក់។ ចំណែកឯការចាត់ចែងជាបណ្តោះអាសន្ន ធ្វើឡើងក្នុងករណីសិទ្ធិត្រូវបានរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទារអោយសងជាប្រាក់។ ទោះជាយ៉ាងណាក៏ដោយ បើនិយាយពីមុខងារការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទមានលក្ខណៈរួមត្រង់ថាមានវិធានការទាំងពីរនេះ គឺជាការចាត់ចែងដែលមានគោលបំណងរក្សាការពារនូវស្ថានភាពបច្ចុប្បន្ន សម្រាប់ការអនុវត្ត[4]ដោយបង្ខំនាពេលអនាគត។ ដោយឡែក ការចាត់ចែងជាបណ្តោះអាសន្នហូតដល់ពេលកំណត់ទំនាក់ទំនងនៃសិទ្ធិជាស្ថាពរ ក្នុងគោលបំណងដកចេញ និងទប់ស្កាត់នូវគ្រោះថ្នាក់ និងការលំបាកនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយភាពយឺតយ៉ាវនៃការកំណត់ទម្រង់នៃសិទ្ធិនោះជាស្ថាពរ។

### ១.១.២ វិសាលភាពនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារមានភាពធំទូលាយ ការអនុវត្តការចាត់ចែងរក្សាការពារ ធ្វើឡើងទៅបានលុះត្រាតែមានដីកាសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច[5]។ ចំពោះការអនុវត្តបានគ្របដណ្តប់លើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន និងបានរួមបញ្ចូលផងដែរចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ វិសាលភាពនៃការអនុវត្ត មានលក្ខណៈធំទូលាយ ផ្អែកលើគោលការណ៍ការពារនូវភាពស្របច្បាប់របស់ដើមបណ្តឹង។

### ១.១.៣ ហេតុដែលនាំឱ្យមានការស្នើសុំរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងដើម្បីការពារសិទ្ធិ និងប្រយោជន៍របស់ម្ចាស់បំណុល ក្នុងការប្រើសិទ្ធិទាមទារបំណុល ដោយយកលិខិតអនុវត្តពីតុលាការទៅអនុវត្តដោយបង្ខំលើកូនបំណុលរបស់ខ្លួន។ ទោះបីជាការចាប់ផ្តើមអនុវត្តដោយបង្ខំតម្រូវឱ្យបំពេញនូវល័ក្ខខ័ណ្ឌ ដូចជាអត្ថិភាពនៃលិខិតអនុវត្ត និងការមកដល់នៃពេលកំណត់សងក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុនដោយមិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែងក្នុងគោលដៅធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ចដូចជា សាលក្រមស្ថាពរជាដើម ហេតុនេះហើយដើម្បីឱ្យ

---

[3] មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[4] ទំព័រ ២២៣ សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ២ នៃព្រះរាជាណាចក្រកម្ពុជា

[5] មាត្រា៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

បានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីថែមទាំងត្រូវការពេលវេលាច្រើន។ ក៏ប៉ុន្តែមុនពេលទទួលសាលក្រមនេះ កូនបំណុលនៃការអនុវត្ត អាចលក់ ឬ ផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលជាហេតុមិនអាចធ្វើ ឬ ធ្វើឱ្យមានការលំបាកដល់ធ្វើការអនុវត្តដោយបង្ខំនៅពេលក្រោយបាន ឬមួយក៏ភាគីណាមួយអាចទទទួលការខូចខាតធ្ងន់ធ្ងរ ឬទទួលគ្រោះថ្នាក់ដល់ឋានៈ របស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិរវាងភាគីទាំងសងខាង។ ក្នុងករណីនេះបុគ្គល ដែលចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារឱ្យមានការចាត់ចែងរក្សាការពារបាន។

## ១.២ ប្រភេទនៃការចាត់ចែងរក្សាការពារក្នុងសំណុំរឿងរដ្ឋប្បវេណី

ការចាត់ចែងរក្សាការពារនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើងដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ចែកចេញជាបីប្រភេទគឺ[6] ៖

- *ការរឹបអូសជាបណ្ដោះអាសន្ន*
- *ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ*
- *ការចាត់ចែងជាចណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន*

### ១.២.១ ការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាវិធានមួយដើម្បីការពារជាបណ្ដោះអាសន្ន នូវសិទ្ធិរបស់ម្ចាស់បំណុល ។ ការរឹបអូសជាបណ្ដោះអាសន្នអាចអនុវត្តចំពោះវត្ថុផ្សេងៗទៀត ដែលជាទ្រព្យសម្បត្តិរបស់កូនបំណុលហើយមានគោលបំណងអោយសងជាប្រាក់ ឬអាចនិយាយម្យ៉ាងទៀតបានថា ការរឹបអូសជាបណ្ដោះអាសន្ន ជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធលើបំណុលមានគោលបំណងឲ្យសងជាប្រាក់[7]។ ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើឡើង ចំពោះអចលនះវត្ថុ និងសិទ្ធិលើបំណុល។

ឧទាហរណ៏ៈ A ជំពាក់ប្រាក់ B ចំនួន ៥០ លានរៀល ។ A ជាកូនបំណុលមានប្រាក់នៅធនាគារ ABA ប្រហែល ៦០លានរៀល ។ នៅក្នុងនីតិវិធីបណ្ដឹងទាមទារប្រាក់កម្ចីនេះ ត្រូវចំណាយពេលវេលាច្រើន ករណីនេះម្ចាស់បំណុលB អាចខូតខាត និងបាត់បង់ផលប្រយោជន៏ក្នុងករណីដែល Aបានទៅធានាគារ ហើយដកយកប្រាក់បញ្ញើទាំងនោះទៅចំណាយអស់ ។ ដូច្នេះដើម្បីការពារផលប្រយោជន៏របស់ខ្លួន B ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននូវគណនីធានាគាររបស់A ដើម្បីអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល

[6] មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[7] មាត្រា៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

B នៅពេលគាត់ឈ្នះក្តី ។ ដូច្នេះ ក្រោយមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន នូវគណនីធានាគាររបស់ A ហើយ Aនឹងមិនអាចទៅធនាគារយកប្រាក់បញ្ញើរបស់ខ្លួនបានទៀតទេ ។

### ១.២.២ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ការចាត់ចែងជាបណ្តោះអាសន្ន គឺជាវិធានមួយដើម្បីការពារការខូចខាតដែលអាចកើតឡើងដោយផ្ទាល់ចំពោះវត្ថុដែលជាវត្ថុនៃវិវាទនោះ។ បើនិយាយឱ្យចំទៅការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានន័យថាជាការចាត់ចែងដើម្បីរក្សានូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តសិទ្ធិដោយសារមានប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ[8]។ ប្រសិនជាម្ចាស់បំណុល មិនបានគិតដល់ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទេ វានឹងបណ្តាលឱ្យមានការលំបាកនៅពេលដែលខ្លួនឈ្នះក្តី។ ផ្ទុយទៅវិញ បើម្ចាស់បំណុលដាក់ពាក្យសុំឱ្យតុលាការធ្វើការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃ វិវាទនោះ វាអាចទប់ស្កាត់នូវការខាតបង់ដែលអាច នឹងកើតឡើងចំពោះខ្លួន ទោះបីជាកូនបំណុលធ្វើការផ្ទេរ ឬ លក់វត្ថុដែលជាកម្មវត្ថុនៃវិវាទទៅអ្នកដទៃក៏ដោយ ក៏កិច្ចសន្យាដែលបានកើតឡើងរវាង កូនបំណុលនិងតតិយជនមិនអាចអះអាងជាមួយម្ចាស់បំណុលបានទេ ពីព្រោះវត្ថុនោះត្រូវបានចាត់ចែងជាបណ្តោះអាសន្នរួចហើយ។ លើសពីនេះទៅទៀត ទោះបីជានៅក្រោយពេលការចាត់ចែងជាបណ្តោះអាសន្ន កូនបំណុលបានយកវត្ថុដែលកម្មវត្ថុនៃវិវាទនោះទៅលក់ ឬ ផ្ទេរក៏ដោយ នៅពេលដែលម្ចាស់បំណុលឈ្នះក្តីគាត់អាចអនុវត្តសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះបានដោយមានអាទិភាព។

ឧទាហរណ៍ៈAបានទិញរថយន្តពីB ក្នុងតម្លៃ២០លានរៀល ។ Aបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យB រួចរាល់ហើយ រង់ចាំតែការផ្ទេរឈ្មោះ ពី B មក A និងការប្រគល់រថយន្តតែប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមកស្រាប់តែមានបញ្ហាដោយដល់កាលកំណត់ដែលត្រូវប្រគល់រថយន្តតាមកិច្ចសន្យាទិញលក់ហើយស្រាប់តែមិនព្រមប្រគល់វិញ។ ដូចនេះភាគី A បានដាក់បណ្តឹងទៅតុលាការ តែនៅក្នុងនីតិវិធីបណ្តឹងនេះតុលាការ អាចប្រើពេលច្រើនក្នុងការកំណត់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធរបស់ A ។ ដូច្នេះនៅអំឡុងពេលនោះ B អាចលក់រថយន្តនោះទៅឱ្យតតិយជនផ្សេងទៀត ដែលជាហេតុធ្វើឱ្យ A ខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះ A ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះរថយន្តនោះ ដើម្បីកុំឱ្យ B ផ្ទេរ ឬលក់រថយន្តនោះទៅតតិយជនបាន ។

[8] មាត្រា៥៣១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ១.២.៣ ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ជានីតិវិធីមួយដើម្បីកំណត់ជាបណ្ដោះអាសន្ននូវឋានៈរបស់ភាគីដែលបានដាក់ពាក្យសុំមុនពេលនីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់ ហើយមួយវិញទៀតអាចនិយាយបានថា វាជាការកំណត់ទៅលើឋានៈបុគ្គលជាបណ្ដោះអាសន្នសិនមុននឹងសាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានការមានភាពចាំបាច់ ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងន់ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[៩]។

ឧទាហរណ៍ៈ លោក A តែងតែធ្វើដំណើរចេញពីផ្ទះតាមផ្លូវតូចដើម្បីទៅដល់ផ្លូវធំ ស្រាប់តែមានពេលមួយនោះ លោក B ដែលជាអ្នកជិតខាងបានមកសាងសង់សំណង់ដោយបិទផ្លូវតូចនោះ ។ ការបិទផ្លូវនេះធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ និង ការរស់នៅប្រចាំថ្ងៃរបស់ លោក A ហេតុដូច្នេះ លោក A បានដាក់ពាក្យសុំទៅតុលាការពិចារណាអំពីការសាងសង់នេះ ដោយសុំឱ្យតុលាការចេញដីកាសម្រេចហាមឃាត់ការសាងសង់ជាបណ្ដោះអាសន្ន ។

## ១.៣ លក្ខណៈទូទៅនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារមានលក្ខណៈបួនដូចខាងក្រោម ៖

### ១.៣.១ លក្ខណៈបណ្ដោះអាសន្ន

ដីកាសម្រេចរក្សាការពារ គឺជានីតិវិធីមួយដែលធ្វើឡើងដោយបណ្ដោះអាសន្ន វាមានន័យថាដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្ដីសម្រេចដោយសាលក្រមក្នុងបណ្ដឹងអង្គសេចក្ដីឡើយ ឬ ធ្វើអោយសេចក្ដីសម្រេចប្រែប្រួលទេ។ ទោះបីដីកាសម្រេចរក្សាការពារដែលចេញដោយតុលាការក៏ដោយ ក៏សិទ្ធលើបំណុល ឬសិទ្ធទាមទារផ្សេងៗទៀតរបស់បណ្ដឹងអង្គសេចក្ដីមិនត្រូវបញ្ជាក់ថា មានអត្ថិភាព ឬនត្ថិភាពឡើយ។

### ១.៣.២ លក្ខណៈបន្ទាន់បង្ខំ

លក្ខណៈបន្ទាន់នៃដីកាសម្រេចរក្សាការពារ ធ្វើឡើងដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងបង្ការកុំឱ្យមានការខូចខាតនូវកម្មវត្ថុនៃវិវាទជាដើម។ ហេតុនេះនីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារ មានលក្ខណៈបន្ទាន់ និងប្រញាប់។ ដើម្បីបំពេញនូវលក្ខណៈបន្ទាន់បង្ខំនេះ ចៅក្រមអាចប្រើប្រាស់នីតិវិធីណាមួយក៏បានក្នុងចំណោមការទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរភាគីនៃបណ្ដឹងតែម្ខាងដែលជាឆន្ទានុសិទ្ធិសម្រេចរបស់លោកចៅក្រមដែលគិតថា ជានីតិវិធីដែលមិនប្រើប្រាស់ពេលវេលាយូរ។

[៩] មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ១.៣.៣ លក្ខណៈបន្ទាប់បន្សំ

នីតិវិធីចាត់ចែងរក្សាការពារ អាចប្រើប្រាស់ជំនួសនីតិវិធីអនុវត្តដោយបង្ខំបាន ក្នុងការធានាដល់សិទ្ធិរបស់ម្ចាស់បំណុល។ ដូចដែលបានរៀបរាប់ក្នុងចំណុចនៃលក្ខណៈបណ្ដោះអាសន្ននៃដីកាសម្រេចចាត់ចែងរក្សាការពារ ជានីតិវិធីមួយដែលបង្កើតឡើងជាបណ្ដោះអាសន្ន ដូច្នេះវាពុំមានឥទ្ធិពល ទៅលើបណ្ដឹងអង្គសេចក្ដីទេ ហើយការកំណត់សមត្ថកិច្ចរបស់តុលាការវាផ្អែកលើបណ្ដឹងអង្គសេចក្ដីប៉ុណ្ណោះ ហេតុដូច្នេះ នីតិវិធីចាត់ចែងរក្សាការពារជាលក្ខណៈបន្ទាប់បន្សំជានីតិវិធីបង។

### ១.៣.៤ លក្ខណៈសម្ងាត់

ដើម្បីបង្ការក្នុង ការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ក្នុងករណីម្ចាស់បំណុលដាក់ពាក្យសុំរក្សាការពារលើចលនវត្ថុ ឬអចលនវត្ថុទាំងនោះ នីតិវិធីនៃការចាត់ចែងរក្សាការពារត្រូវតែរក្សាការសម្ងាត់ជូនម្ចាស់បំណុល។ ម្យ៉ាងវិញទៀត ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារពុំចាំបាច់មានការបញ្ជូនទៅកូនបំណុលឡើយ។ ខុសពីនីតិវិធីបណ្ដឹងអង្គសេចក្ដី ដែលតម្រូវអោយមានការបញ្ជូនដីកានានាដល់កូនបំណុលដើម្បីទទួល និងដឹងអំពីពត៌មានផ្សេងៗ នេះសបញ្ជាក់អោយឃើញផងដែរអំពីលក្ខណៈសម្ងាត់របស់ដីកាសម្រេចរក្សាការពារ។

## ១.៤ សមត្ថកិច្ចរបស់តុលាការចំពោះការចាត់ចែងរក្សាការពារ

ការកំណត់សមត្ថកិច្ចរបស់តុលាការនេះ ពីព្រោះតែតុលាការមានច្រើន។ បើមិនបានកំណត់សមត្ថកិច្ចទេ វាអាចនឹងមានការជាន់សមត្ថកិច្ច។ តុលាការដែលមានសមត្ថកិច្ចនៅក្នុងរឿងក្ដីចាត់ចែងរក្សាការពារ វាជាសមត្ថកិច្ចផ្ដាច់មុខ។ ហេតុនេះហើយ ការព្រមព្រៀងរបស់ភាគីក្នុងការផ្លាស់ប្ដូរតុលាការគឺមិនអាចធ្វើទៅរួចឡើយ។ ហើយតុលាការនោះត្រូវបានបែងចែកទៅតាមសមត្ថកិច្ចដូចខាងក្រោម ៖

### ១.៤.១តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី

តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការនៃតុលាការជំនុំជម្រះលើកទី១។ ប៉ុន្តែបើអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[10]។ បើអង្គសេចក្ដីត្រូវបានចាត់ការនៅឯតុលាការកំពូល ដោយត្រឡប់ទៅរកគោលការណ៍វិញ តុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីនៃដីកាសម្រេចរក្សាការពារ គឺជាតុលាការនៃការជំនុំជំរះលើកទី១។

[10] មាត្រា៥៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

**១.៤.២.សាលាដំបូងមានសមត្ថកិច្ចលើវត្ថុដែលនឹងត្រូវរឹបអូស ឬ កម្មវត្ថុនៃវិវាទ**

រឿងក្តីនៃការសម្រេចរក្សាការពារត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុដែលវិវាទស្ថិតនៅ[11]។

[11] មាត្រា៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

# ជំពូកទី២

# ការអនុវត្តដីកាសម្រេចរក្សាការពារ

## ២.១ ដីកាសម្រេចរក្សាការពារ

### ២.១.១ ការដាក់ពាក្យសុំចេញដីការក្សាការពារ

នៅក្នុងការដាក់ពាក្យសុំរក្សាការពារនេះ មិនត្រឹមតែគោរពទៅតាមចំនុចដែលត្រូវសរសេរនៅក្នុងពាក្យសុំនោះទេ លើសពីនេះទៅទៀតត្រូវចំណាយសោហ៊ុយសម្រាប់នីតិវិធីផងដែរ។

#### ២.១.១.១ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ការដាក់ពាក្យសុំមិនមែនចេះតែសរសេរនោះទេ គឺត្រូវធ្វើតាមទំរង់ដែលមានការសរសេរជាលាយលក្ខណ៍អក្សរហើយចំណុចដែលត្រូវសរសេរមានដូចខាងក្រោម[12]៖

- ឈ្មោះ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ
- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ
- ភាពចាំបាច់នៃការរក្សាការពារ
- ភស្តុតាងតាមហេតុនីមួយៗ[13]។

**ក ឈ្មោះនិងអាសយដ្ឋានរបស់ភាគី និង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់**

នៅក្នុងពាក្យសុំ ឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរឱ្យបានច្បាស់លាស់ អំពីឈ្មោះ និងអាសយដ្ឋានរបស់ខ្លួន ហើយប្រសិនបើម្ចាស់បំណុលមិនបានដាក់ពាក្យដោយផ្ទាល់ទេ ត្រូវមានលិខិតបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ហើយអ្នកតំណាងនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ ក៏មិនខុសអ្វីពីនីតិវិធីនៃបណ្តឹងអង្គសេចក្តីដែរ មានន័យថាម្ចាស់បំណុលមានសិទ្ធិក្នុងការជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបាន។ជាធម្មតាអ្នកតំណាងដោយអាណត្តិគឺជាមេធាវី លើកលែងតែករណីមួយចំនួនដូចខាងក្រោម៖ ករណីដែលក្រមនេះ ឬច្បាប់ដទៃទៀតអនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី។ ករណីដែលភាគីជា រដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬស្ថាប័នរដ្ឋដទៃទៀត និងដែលស្ថាប័ននោះ ឬអ្នកតំណាងនៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័

[12] មាត្រា៥៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[13] មាត្រា៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

ននោះជាអ្នកតំណាង។ ករណីដែលតុលាការអនុញ្ញាត ឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្តីដែលតម្លៃកម្មវត្ថុនៃបណ្តឹងតិចជាងមួយលានរៀល[14]។

ការតំណាងដោយអាណត្តិ តម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ ហើយសិទ្ធិត្រូវបានផ្តល់ឱ្យអ្នកតំណាងដោយអាណត្តិតាមរយៈលិខិតប្រគល់សិទ្ធិ[15]។

**ខ ខ្លឹមសារលម្អិតនៃដីកាសម្រេចក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ**

ខ្លឹមសារលម្អិតនៃដីកាសម្រេចរក្សាការពារនេះ អ្នកដាក់ពាក្យសុំត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃដីកាសម្រេចរក្សាការពារ ដែលខ្លួនចង់ឱ្យតុលាការចេញដីកាសម្រេច ដែលប្រភេទនៃដីកាសម្រេចនោះមានដូចខាងក្រោមៈ

-*<u>ដីកាសម្រេចរក្សាការពាររឹបអូសជាបណ្តោះអាសន្ន</u>*

-*<u>ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ</u>*

-*<u>ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន</u>*។

**គ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ**

វាជាការចាំបាច់បំផុត ដែលត្រូវសរសេរអំពីអង្គហេតុដែលជា មូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ផ្សេងៗទៀត បើសិនជាមានដោយសារតែការសរសេរអំពីអង្គហេតុទាំងពីរនេះគឺ ដើម្បីបង្កើតសិទ្ធិ។

**ឃ ភាពចំបាច់នៃការរក្សារការពារ ពាក្យសុំដីការរក្សារការពារ**

ម្ចាស់បំណុល ត្រូវធ្វើយ៉ាងណាសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងពាក្យសុំ ដើម្បីបង្ហាញពីភាពចាំបាច់ ឬហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីឱ្យចៅក្រមយល់ព្រមចេញដីកាសម្រេចនោះ។ ហើយអ្វីដែលសំខាន់ គឺបញ្ហាប្រឈមរបស់ម្ចាស់បំណុល ប្រសិនបើតុលាការមិនចេញដីកាសម្រេចរក្សាការពារទេ។

**ខ ភស្តុតាង**

ភស្តុតាងក្នុងន័យធម្មតា ជាឯកសារ និងវត្ថុតាងជាអាទិ៍ ដែលមានភាពសំខាន់សម្រាប់បញ្ជាក់អង្គហេតុ ហើយការទទួលអង្គហេតុត្រូវផ្អែកលើភស្តុតាង។ នៅពេលដាក់ពាក្យសុំ ដីកាសម្រេចរក្សាការពារម្ចាស់បំណុលគប្បីសរសេរឱ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាង ដែលបញ្ជាក់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចំបាច់នៃការរក្សាការពារ ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងការស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង[16]។ ជាធម្មតាទេ ម្ចាស់បំណុល ឬអ្នកដាក់ពាក្យនៅពេលដែលខ្លួនដាក់

[14] មាត្រា៥៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[15] មាត្រា៥៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[16] មាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

ពាក្យសុំមានគោលបំណងតែមួយគត់ គឺចង់ឱ្យតុលាការធ្វើតាមពាក្យសុំរបស់ខ្លួន។ ហេតុនេះហើយ ភស្តុតាងមានសារៈសំខាន់ណាស់ ដើម្បីជួយសម្រេចគោលបំណងរបស់អ្នកដាក់ពាក្យសុំ ដែលអ្នកដាក់ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវភស្តុតាង ដែលមានទាំងអស់ដែលអ្នកដាក់ពាក្យសុំមាន អាចជា បញ្ជីភាគី បញ្ជីសិទ្ធិលើបំណុល បញ្ជីសារពើភ័ណ្ឌអំពីទ្រព្យសម្បត្តិដែលត្រូវរឹបអូសជាដើម។

**២.១.២ សោហ៊ុយ**

សោហ៊ុយនេះត្រូវបានបែងចែកជាពីរ ដូចខាងក្រោម ៖

-ពន្ធដាក់ពាក្យសុំ

-ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ។

**២.១.២.១ ពន្ធដារពាក្យសុំ**

ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០រៀល[17] ។

បើពន្ធពាក្យសុំខាងលើមិនត្រូវបានបង់ទេ តុលាការត្រូវបង្គាប់ម្ចាស់បំណុលបង់ពន្ធពាក្យសុំ ក្នុងអំឡុងពេលសមរម្យ។ បើម្ចាស់បំណុលមិនបង់ពន្ធពាក្យសុំតាមការបង្គាប់របស់តុលាការទេ តុលាការត្រូវលើកពាក្យសុំចោលដោយដីកាសម្រេច[18]។

**២.១.២.២ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ**

បន្ថែមលើពន្ធពាក្យសុំដែលបានលើកឡើងខាងលើ ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំ ត្រូវបង់ប្រាក់ប្រដាប់ក្ដីតុលាការផ្សេងទៀតក្រៅពីពន្ធ សម្រាប់នីតិវិធីដូចខាងក្រោមនេះ៖

-ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី។

-ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែលត្រូវទៅនៅក្រៅតុលាការ។

-ប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាពដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាព ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់[19]។

[17] មាត្រា៥៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[18] មាត្រា៥៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[19] មាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

#### ២.១.២.៣ បន្ទុកនៃប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីជាទូទៅជាបន្ទុករបស់ភាគីចាញ់ក្ដី[20]។ ប៉ុន្តែដោយសារតែតុលាការនៅក្នុងរឿងរដ្ឋប្បវេណី តុលាការ គឺជាតុលាការអកម្ម ហេតុនេះហើយម្ចាស់បំណុលគួរតែស្នើសុំជាមុននៅក្នុងពាក្យបណ្ដឹងរបស់ខ្លួនដើម្បីឱ្យតុលាការវិនិច្ឆ័យ។

### ២.១.៣ ប្រភេទនៃដីកាសម្រេចរក្សាការពារ

ប្រភេទនៃដីកាសម្រេចរក្សាការពារ វាមិនខុសគ្នាពីការចាត់ចែងរក្សាការពារនោះទេ គ្រាន់តែដីកាសម្រេចរក្សាការពារ គឺជាសេចក្ដីសម្រេចរបស់តុលាការដែលចេញ នៅពេលដែលមានពាក្យសុំឱ្យចាត់ចែងរក្សាការពារ ហើយដីកាសម្រេចនេះមានពីរដូចខាងក្រោម៖

<u>-ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន</u>

<u>-ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន</u>

ហើយដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននេះ ចែកចេញជាពីរទៀត គឺការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

#### ២.១.៣.១ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារនេះ មិនមែនសរសេរតាមការនឹកឃើញនោះទេ ប៉ុន្តែតុលាការត្រូវសរសេរនូវចំណុចនីមួយៗ ដែលច្បាប់បានចែងទុកជាមុន។

**ក ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី**

- មុនពេលចេញដីកាសម្រេចរក្សាការពារតុលាការត្រូវសរសេរនូវចំណុចចាំបាច់មួយចំនួនដូចខាងក្រោម៖ អត្តសញ្ញាណនៃភាគី ហើយអត្តសញ្ញាណនេះដែរ គឺមានទាក់ទងទៅនឹងភាគីដូចជា ឈ្មោះនិងអាសយដ្ឋានរបស់ភាគី និង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃសិទ្ធិលើបំណុលដែលបានទាមទារ ត្រង់ចំណុចនេះដែរ គឺមានទាក់ទងទៅនឹងសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ។ ហើយទាក់ទងទៅនឹងកម្មវត្ថុដែលត្រូវរក្សាការពារ ដែលវាជាចំណុចចាំបាច់សម្រាប់បញ្ជាក់រឿងក្ដីផងដែរ។ ហើយម្យ៉ាងវិញទៀត ដោយសារតែដីកាសម្រេចរក្សាការពារត្រូវបានចេញដោយផ្អែកលើពាក្យសុំ។ ដូច្នេះកាចេញដីកាសម្រេចរក្សាការពារ តុលាការមិនមែនចេញខុសសាច់រឿង ឬក៏អ្វី

[20] មាត្រា៦៤ កថាខណ្ឌទី១ វាក្យខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

ដែលគេមិនបានសុំឡើយ[21]។ នៅក្នុងរឿងក្តីរដ្ឋប្បវេណីតុលាការជា តុលាការអកម្ម មិនដូចជាតុលាការក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ។

**ខ ការសរសេរបញ្ជាក់នូវកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ហើយជាពិសេសបំផុត គឺចំពោះអចលនវត្ថុត្រូវកំណត់ឱ្យបានជាក់លាក់[22]។ ហើយភាពជាក់លាក់នៃកម្មវត្ថុចំពោះអចលនវត្ថុ សំដៅទៅលើព័ត៌មានសំខាន់ៗដែលរួមមាន ឯកសារដែលចេញដោយការិយាល័យជំនាញភូមិបាលដែលនិយាយឱ្យចំទៅ គឺសំដៅទៅលើ បណ្ណកម្មសិទ្ធិ លើអចលនវត្ថុរបស់កូនបំណុលតែម្តង ក្នុងករណីដែលម្ចាស់បំណុលរកបាន។ ជាមួយគ្នានេះដែរ បើចំពោះចលនវត្ថុវិញ វាក៏ពុំមានភាពចាំបាច់ពេកនោះទេ តែបើអាចកំណត់បានក៏វាជាការល្អម្យ៉ាងដែរ។ ដើម្បីឱ្យមានភាពងាយស្រួលដែលអាចជាលេខរថយន្ត ប្រភេទរថយន្ត សេរីឆ្នាំណា ពណ៌អ្វី ផលិតនៅប្រទេសណា ស្ថានភាពបច្ចុប្បន្នរបស់រថយន្ត និងនរណាជាម្ចាស់កម្មសិទ្ធិ។ ដូចដែលបានបញ្ជាក់ពីខាងដើម ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន វាមានទៅលើចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល ឬ ទ្រព្យសម្បត្តិផ្សេងទៀត។ ដូច្នេះដើម្បីឈានទៅធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិបាន តម្រូវឲ្យមានការកំណត់ជាក់លាក់នូវព័ត៌មានទាំងអស់ ពាក់ព័ន្ធទៅនឹងអចនវត្ថុនោះតាំងនៅ។ ផ្ទុយទៅវិញ ចំពោះចលនវត្ថុពេលអនុវត្តដីកាសម្រេច គឺអាជ្ញាសាលានឹងចុះទៅដល់ទីតាំងអចលនវត្ថុនោះតាំងនៅរួច ធ្វើការរឹបអូសអចលនវត្ថុតែម្តង។

### ២.១.៤ លក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ

ការចេញដីកាសម្រេចរក្សាការពារ មិនមែនតុលាការចេះតែធ្វើទៅតាមពាក្យសុំរបស់ម្ចាស់បំណុលនោះទេ មុននឹងចេញដីកាសម្រេចនីមួយៗ តុលាការបានគិតគូយ៉ាងល្អិតល្អន់ទៅលើសិទ្ធិ ដែលត្រូវបានរក្សាការពារនិងភាពចាំបាច់នៃការរក្សាការពារ។

#### ២.១.៤.១ សិទ្ធិដែលត្រូវបានរក្សាការពារ

សិទ្ធិដែលត្រូវបានរក្សាការពារនេះ គឺវាអាស្រ័យលើប្រភេទនៃដីកាសម្រេចរក្សាការពារដូចខាងក្រោម៖

**ក ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងអោយសងជាប្រាក់[23]។ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ សិទ្ធិទាមទារ ដែលកើតចេញពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើចង់សម្រេចដោយឱ្យសង

[21] មាត្រា៥៣១ ចំនុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[22] មាត្រា៥៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[23] មាត្រា៥៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

ឬបង់ប្រាក់ ក៏អាចសុំឱ្យចាត់ចែងរក្សាការពារតាមរយៈការរឹបអូសជាបណ្ដោះអាសន្នបានដែរ ហើយសិទ្ធិដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹង លក្ខខណ្ឌ ឬពេលកំណត់។ ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់លក្ខខណ្ឌបង្អង់ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ។

**ខ.ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

វាជាសិទ្ធិ ដែលមានគោលបំណងដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុ ដែលជាកម្មវត្ថុនៃវិវាទនោះ[24]។ ហើយសិទ្ធិដែលត្រូវរក្សាការពារនោះ រួមមានសិទ្ធិទាមទារឱ្យប្រគល់វត្ថុ សិទ្ធិទាមទារឱ្យបណ្ដេញបុគ្គលចេញពីដី ឬអាគារ សិទ្ធិទាមទារឱ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពពាក់ព័ន្ធ និងការប្រើប្រាស់វត្ថុជាអាទិ៍។

**គ.ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន**

សិទ្ធិដែលត្រូវបានរក្សាការពារ ចំពោះការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ននេះ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល។ ឧទាហរណ៍ៈ ទំនាក់ទំនងសិទ្ធិផ្តាច់មុខដូចជា កម្មសិទ្ធិ សិទ្ធិកាន់កាប់ សេវភាព សិទ្ធិលើនាម និងសិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្សដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និងកម្មសិទ្ធិអវិភាគ ទំនាក់ទំនងគតិយុត្តដែលបន្ត ដូចជាកិច្ចសន្យាក្រុមហ៊ុនភតិសន្យាការងារ និងការផ្គត់ផ្គង់អាហារកាតព្វកិច្ច និងទំនាក់ទំនងឋានៈបុគ្គលដូចជា ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងរវាងឪពុកម្ដាយ និងកូនៗ ។

**២.១.៤.២ ភាពចាំបាច់នៃការរក្សាការពារ**

មុននឹងចេញដីកាសម្រេចរក្សាការពារតុលាការ ត្រូវពិចារណាហើយពិនិត្យទៅលើលក្ខខណ្ឌពីរ ដែលទីមួយសិទ្ធិដែលត្រូវបានរក្សាការពារដូចដែលបានរៀបរាប់ខាងលើរួមមកហើយ។ ឯមួយទៀត គឺភាពចាំបាច់នៃការរក្សាការពារ ហើយភាពចាំបាច់វាអាស្រ័យទៅលើប្រភេទនៃដីកាសម្រេចរក្សាការពារផងដែរដូចខាងក្រោមៈ

**ក.ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

ការរឹបអូសជាបណ្ដោះអាសន្ន តុលាការចេញដីកាសម្រេចនេះមិនត្រឹមតែផ្អែកលើសិទ្ធិ ដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ ហើយថែមទាំងផ្អែកទៅលើភាពចាំបាច់នៃការរក្សាការពារទៀតផង។ ការរឹបអូសជាបណ្ដោះអាសន្ន ត្រូវចាត់ទុកថាចាំបាច់ក្នុងករណីដែល ការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្ដោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែល[25]។

[24] មាត្រា៥៣១ ចំនុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[25] មាត្រា៥៤៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

**ខ.ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

ការចាត់ចែងជាបណ្តោះអាសន្ន ត្រូវចាត់ទុកថាចាំបាច់ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ[26]។ យ៉ាងណាមិញដូចជា ការខូចខាត ការគៃបំបាត់ ការផ្ទេរ ការរារាំងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃវិវាទជាដើម។

**គ.ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន**

ភាពចាំបាច់នៃ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នក្នុងករណីដែលមានភាពចាំបាច់ ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដោយម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[27]។

## ២.២ ប្រាតិភោគ

ប្រាតិភោគ ក្នុងន័យទូទៅអាចមានពីរអត្ថន័យ ដែលទី១គឺជាការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ។ រីឯអត្ថន័យមួយទៀត គឺជាមធ្យោបាយដើម្បីធានាការសងកាតព្វកិច្ច[28]។ ដីកាសម្រេចរក្សាការពារអាចធ្វើឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន វាអាស្រ័យទៅតាមការពិចារណារបស់ចៅក្រម ថាតើម្ចាស់បំណុលគួរឱ្យដាក់ប្រាតិភោគ ឬមិនគួរឱ្យដាក់ប្រាតិភោគ[29]។ ការដាក់ប្រាតិភោគនេះសំដៅដល់ការដាក់ប្រាតិភោគដែលម្ចាស់បំណុលត្រូវដាក់ ឬមិនត្រូវដាក់តាមឆន្ទានុសិទ្ធិ ដូចដែលបានរៀបរាប់មកហើយ។ ប៉ុន្តែការដាក់ប្រាតិភោគ មិនមែនធ្វើឡើងចំពោះតែម្ចាស់បំណុលនោះទេ គឺថាការបង្គាប់ឱ្យដាក់ប្រាតិភោគនេះ តុលាការអាចឱ្យកូនបំណុលដាក់ប្រាតិភោគផងដែរ ក្នុងករណីដែលតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ បន្ទាប់ពីតុលាការចេញសេចក្តីសម្រេច អំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ[30]។

### ២.២.១ គោលបំណងនៃប្រាតិភោគ

នីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារបាន ដោយមិនចាំបាច់សួរកូនបំណុលដោយគ្រាន់តែឆ្លងកាត់ធ្វើសេចក្តីបញ្ជាក់ដំបូង។ ប៉ុន្តែជួនកាលដីកាសម្រេចរក្សាការពារ វាក៏ជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ផលប្រយោជន៍របស់កូនបំណុលផងដែរ ដោយហេតុនេះហើយ ទើបតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។

---

[26] មាត្រា៥៤៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[27] មាត្រា៥៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[28] សន្ទានុក្រមផ្នែករដ្ឋប្បវេណី,១០១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

[29] មាត្រា៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[30] មាត្រា៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

គោលបំណងរបស់វា គឺដើម្បីទប់ស្កាត់ការប្រើប្រាស់សិទ្ធិហួសប្រមាណរបស់ម្ចាស់បំណុល បើនិយាយឱ្យចំទៅ គោលបំណងដែលតុលាការឱ្យដាក់ប្រាតិភោគ គឺដើម្បីធានាការសងការខូចខាត ដែលកូនបំណុលបានទទួលរង។ មួយវិញទៀត កូនបំណុលនឹងមានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត[31]។ ប៉ុន្តែក្នុងករណីដែលតុលាការបានចេញដីកាសម្រេចមិនបានបង្គាប់អោយដាក់ប្រាតិភោគ វាអាចនឹងមានការលំបាកផងដែរចំពោះកូនបំណុល ក្នុងការទាមទារសំណងនៃការខូចខាត ដែលកើតឡើងដោយសារដីកាសម្រេចរក្សាការពារ។ បើទោះបីជា កូនបំណុលអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាមរយៈអំពើអនីត្យានុកូលក៏ដោយ ពីព្រោះបើម្ចាស់បំណុលមានទ្រព្យសម្បត្តិសម្រាប់រឹបអូសវាជាការប្រសើរ។ ផ្ទុយទៅវិញ បើម្ចាស់បំណុលមិនមានអ្វីសោះនោះ វាពិតជាមានការលំបាកចំពោះកូនបំណុល ក្នុងការទាមទារសំណងការខូចខាតដែលកើតឡើង ដោយសារដីកាសម្រេចរក្សាការពារនោះ[32]។

### ២.២.២ ចំនួននៃប្រាតិភោគ

ចំនួននៃប្រាតិភោគនេះ តុលាការអាចសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការត្រូវពិចារណាជាមុនឱ្យបានល្អិតល្អន់លើផលប៉ះពាល់ ដែលនាំឱ្យមានការខូចខាតនៅពេលតុលាការចេញ ដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់ម្ចាស់បំណុល ឬលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំតវ៉ារបស់កូនបំណុល។ ហេតុនេះហើយ តុលាការត្រូវធ្វើការវាយតម្លៃលើការខូចខាត ដែលអាចនឹងកើតមានដល់កូនបំណុល ឬម្ចាស់បំណុល។ ដូច្នេះមុននឹងចេញដីកាសម្រេចរក្សារការពារ គឺតុលាការពិនិត្យលើឯកសារនៃសេចក្ដីបញ្ជាក់ដំបូង និងសួរម្ចាស់បំណុល ឬពិនិត្យឯកសារ និងសួរកូនបំណុល ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារ ឬម្ចាស់បំណុល ក្នុងករណីដែលតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុលមានន័យថា បើការបញ្ជាក់ដំបូងមានភាពរឹងមាំនោះ ចំនួននៃប្រាតិភោគក៏តិចទៅតាមនោះដែរ ប៉ុន្តែបើសេចក្ដីបញ្ជាក់ដំបូងពុំមានភាពរឹងមាំនោះការប្រាតិភោគក៏ច្រើនដែរ។

### ២.២.៣ វិធីនៃការដាក់ប្រាតិភោគ

ការដាក់ប្រាតិភោគនេះ មិនមែនចេះតែដាក់នោះទេគឺលុះត្រាតែតុលាការបង្គាប់ឱ្យដាក់ ហើយការដាក់ប្រាតិភោគនេះ ជាលក្ខខណ្ឌមួយដែលស្ថិតនៅក្នុងការពិចារណារបស់តុលាការដើម្បីចេញដីកាសម្រេចរក្សាការពារ។ ហេតុនេះហើយ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគមុនចេញដីកាសម្រេចរក្សាការពារ។ បើមិនដូច្នេះទេ ម្ចាស់បំណុលនឹងមិនអាចសម្រេចគោលបំណងរបស់ខ្លួនបានឡើយ លុះត្រាម្ចាស់បំណុលដាក់ប្រាតិភោគតាមការបង្គាប់របស់តុលាការ។ ប្រាតិភោគត្រូវមានអានុភាពដោយការផ្ញើប្រាក់ ឬ ឧបករណ៍ដែលអាច

---

[31] មាត្រា៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[32] មាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ជួញដូរបានដែលតុលាការទទួលស្គាល់ថា សមរម្យទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ឬតុលាការអនុវត្ត រក្សាការពារ[33]។ ចំពោះការផ្តល់នូវប្រាតិភោគ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបានដើម្បីឱ្យអ្នកមានសិទ្ធិលើប្រាតិភោគអាចទាមទារយកប្រាតិភោគដែលបានដាក់។

## ២.៣ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

ដើម្បីឲ្យបានរួចផុតពីការរឹបអូសជាបណ្តោះអាសន្ន កូនបំណុលត្រូវផ្ញើប្រាក់ ដើម្បីធ្វើការដោះដូរជាមួយកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។

### ២.៣.១ គោលបំណងនៃប្រាក់រំដោះ

ដីកាសម្រេចរក្សាការពារ ដែលទាក់ទងទៅនឹងការរឹបអូសជាបណ្តោះអាសន្ន ដែលអាចនិយាយបានថាជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ការដែលតម្រូវឱ្យកូនបំណុលដាក់ប្រាក់រំដោះ បើកូនបំណុល ចង់ឱ្យកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នរួចផុតពីការរឹបអូសជាបណ្តោះអាសន្ន។ ហេតុនេះហើយកូនបំណុលត្រូវផ្ញើប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ឬ ចំនួនទឹកប្រាក់នៃកម្មវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ន។ គោលបំណងនៃប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននេះ គឺដើម្បីការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលបានផ្ញើប្រាក់តាមការកំណត់របស់តុលាការកូនបំណុលអាចរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។ ប្រាក់រំដោះ គឺដើម្បីជំនួសទ្រព្យដែលត្រូវបានរឹបអូស ដូច្នេះប្រាក់រំដោះត្រូវស្ថិតនៅក្នុងការអនុវត្តរបស់ម្ចាស់បំណុល។

### ២.៣.២ ចំនួននៃប្រាក់រំដោះ

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវធ្វើដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន[34]។ វាជាឆន្ទានុសិទ្ធិ របស់ចៅក្រមក្នុងការសម្រេចអំពីចំនួននៃប្រាក់រំដោះ ពីការរឹបអូសជាបណ្តោះអាសន្ន ដោយពិចារណាទៅលើតម្លៃនៃទ្រព្យសម្បត្តិ ដែលម្ចាស់បំណុលធ្វើការស្នើសុំរឹបអូស និងចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវបានរឹបអូស ជាបណ្តោះអាសន្នពីព្រោះតែប្រាក់រំដោះនេះ គឺជាប្រាក់មួយប្រភេទសម្រាប់ធ្វើជំនួសនូវទ្រព្យសម្បត្តិដែលបានរឹបអូសជាបណ្តោះអាសន្ន។ ហើយម្យ៉ាងទៀត តុលាការត្រូវធ្វើយ៉ាងណាឱ្យមានសមភាពរវាងសិទ្ធិលើបំណុល ឬចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវរឹបអូស និងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នដែលកូនបំណុលបានផ្ញើ។

---

[33] មាត្រា៥៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[34] មាត្រា៥៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ២.៣.៣ វិធីនៃការដាក់ប្រាក់រំដោះ

ការផ្ញើប្រាក់រំដោះ ពីការរឹបអូសជាបណ្តោះអាសន្ននេះ កូនបំណុលត្រូវផ្ញើទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្តរក្សាការពារ[35] ហើយនីតិវិធីលម្អិតនៃការផ្ញើប្រាក់រំដោះនេះពុំទាន់មានច្បាប់នៅឡើយ ដែលក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាង។

## ២.៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ

នៅពេលចេញដីកាសម្រេចរក្សាការពារតុលាការ ត្រូវបញ្ជូនដីកាសម្រេចរក្សាការពារនោះទៅឱ្យភាគីទាំងនោះ[36]។

### ២.៤.១ ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ

ការបញ្ជូនដីកាសម្រេចបង្គាប់ឱ្យរក្សាការពារនេះ គឺមានគោលបំណងដើម្បីឱ្យភាគីបានដឹងអំពីសេចក្តីសម្រេចនៃដីការក្សាការពារ ហើយវាក៏ជាការផ្តល់ឱកាសឱ្យកូនបំណុលធ្វើការតវ៉ា។ ដើម្បីចៀសវាងនូវការរារាំងរបស់កូនបំណុល និងការធានានូវការអនុវត្តរក្សាការពារ តុលាការអាចនឹងមិនបញ្ជូនដីកាសម្រេចនោះទៅកូនបំណុល។

### ២.៤.២ ដីកាសម្រេចលើកចោលពាក្យសុំ

ក្នុងករណី ដែលតុលាការលើកចោលពាក្យសុំរបស់ម្ចាស់បំណុល ដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារគឺមិនចាំបាច់ញូនឱ្យទៅកូនបំណុលទេ ដោយសារតែពុំមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុល។ ប៉ុន្តែក្នុងករណីដែលតុលាការធ្វើការសួរ ឬ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចំពោះភាគីនោះ តុលាការក៏ត្រូវបញ្ជូនទៅកូនបំណុលផងដែរ[37]។ ហើយតុលាការត្រូវតែបញ្ជូនដីកាសម្រេចដែលលើកពាក្យសុំចោលទៅម្ចាស់បំណុល ពីព្រោះវាក៏ជាការផ្តល់ដំណឹងដល់ម្ចាស់បំណុល ដើម្បីឱ្យម្ចាស់បំណុលធ្វើបណ្តឹងជំទាស់នូវសេចក្តីសម្រេចរបស់តុលាការ។

## ២.៥ ការអនុវត្តការរក្សាការពារចំពោះអចលនវត្ថុ

### ២.៥.១ លក្ខខណ្ឌក្នុងការអនុវត្ត

ក្រោយពេលទទួលបានដីការក្សាការពាររួចមក ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។ "ចំពោះការកំណត់បែបនេះ គឺជាការគិតគូរដល់ហានិភ័យរបស់ម្ចាស់បំណុលដែលនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តនាពេលអនាគត ប្រសិនបើមិនមានវិធានការអន្តរាគមន៍ទាន់ពេលវេលាទេ ឬអាចនិយាយបានថា បើមិនឱ្យ

[35] មាត្រា៥៤៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[36] មាត្រា៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[37] មាត្រា២១៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

ដីកាសម្រេចនេះមានអនុភាពភ្លាមទេ វាមិនឆ្លើយតបទៅនឹងភាពចាំបាច់ នៃការរក្សាការពារសិទ្ធិទាមទាររបស់ម្ចាស់បំណុលក្នុងការអនុវត្តចំពោះកូនបំណុលនៃការអនុវត្តឡើយ។ ទោះបីជាមាន ដីការក្សាការពារយ៉ាងណាក៏ដោយបើសិនជាម្ចាស់បំណុលមិនបានដាក់ពាក្យសុំអនុវត្តជាបន្ទាន់ទៅតុលាការអនុវត្ត ឬ អាជ្ញាសាលានៃវត្ថុដែលជាកម្មវត្ថុនៃការរក្សាការពារស្ថិតនៅទេ ដីកាសម្រេចនោះគឺគ្មានន័យ។ ដោយសារថា បើហួសអំឡុងពេល ២ សប្តាហ៍នៃការអនុវត្តដែលបានកំណត់នៅក្នុងច្បាប់ ដីកាសម្រេចនោះមិនអាចអនុវត្តបានទៀតទេ។ ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ ត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយត្រូវភ្ជាប់មកជាមួយលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។ អ្នកដាក់ពាក្យសុំមិនបាច់ស្នើសុំរូបមន្តអនុវត្តទេ ពីព្រោះថាការរក្សាការពារជាបញ្ហាបន្ទាន់បង្ខំ ហេតុនេះត្រូវអនុវត្តឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ក៏ប៉ុន្តែបើសិនជាការអនុវត្តចំពោះ ឬសម្រាប់ជនក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងដីការសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីការសម្រេចរក្សាការពារ ដែលភ្ជាប់ជាមួយនិងរូបមន្តអនុវត្ត។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មានមេធាវីដែលតំណាងឱ្យខ្លួនពាក្យសុំអនុវត្តនោះ ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិផងដែរ។ ប៉ុន្តែបើមាន លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះរួចហើយនៅក្នុងបណ្តឹងអង្គសេចក្តី ហេតុនេះមិនចាំបាច់ភ្ជាប់មកជាមួយម្តងទៀតទេ។

## ២.៥.២ ស្ថាប័នមានសមត្ថកិច្ច

### ២.៥.២.១ អាជ្ញាសាលា

អាជ្ញាសាលាគឺជាមន្ត្រីអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។ ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត[38]។ អាជ្ញាសាលាមានតួនាទី និងភារកិច្ចច្រើនក្នុងនោះ ពេលខ្លះអាជ្ញាសាលាអនុវត្តតួនាទីក្នុងនាមជា ស្ថាប័នឯករាជ្យ និងពេលខ្លះអាជ្ញាសាលាអនុវត្តកិច្ចការជាជំនួយការរបស់តុលាការ។ នៅក្នុងការអនុវត្តដោយបង្ខំ ឬការរឹបអូសជាបណ្តោះអាសន្ន ដែលមានគោលបំណងឱ្យសងជាប្រាក់ អាជ្ញាសាលាមានសមត្ថកិច្ច ចំពោះតែចលនវត្ថុតែប៉ុណ្ណោះ។ ចំណែកឯការអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់ទេ អាជ្ញាសាលា អាចអនុវត្តសិទ្ធិអំណាចរបស់ខ្លួន តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្នុងការទាមទារឱ្យប្រគល់ចលនវត្ថុ អចលនវត្ថុ និងនាវាបាន[39]។

### ២.៥.២.២ តុលាការអនុវត្ត

[38] ប្រកាសលេខ៣០ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០៧

[39] មាត្រា ៥២៤ និង មាត្រា ៥២៥ នៃក្រមរដ្ឋប្បវេណី

តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តរក្សាការពារ។ តុលាការអនុវត្តរក្សាការពារ ជាតុលាការសាលាដំបូងតាមរាជធានីខេត្តនីមួយៗ ដោយហេតុថាតុលាការនេះសមត្ថកិច្ចនៅក្នុងដែនដីនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ។ តុលាការអនុវត្ត មានសមត្ថកិច្ចអនុវត្តរក្សាការពារ ចំពោះអចលនវត្ថុ សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងនាវា។

### ២.៥.៣ ការរឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុ

អចលនវត្ថុ នៅក្នុងក្រមរដ្ឋប្បវេណីអចលនវត្ថុសំដៅលើ ដីធ្លី និងវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ទីកន្លែងបានដូចជា អាគារ សំណង់ រុក្ខជាតិជាអាទិ៍។ នៅក្នុងការអនុវត្តរឹបអូសជាបណ្តោះអាសន្នអចលនវត្ថុសំដៅលើអាគារដែលត្រូវបានចុះបញ្ជី ចំណែកឯកម្មសិទ្ធិអរិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ តុលាការដែលបានចេញដីកាសម្រេចអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះទៅ។ ចំណែកក្រឡាបញ្ជី ត្រូវផ្ញើកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ហើយការផ្ញើកផ្តាក់នេះត្រូវអនុវត្តឱ្យបានឆាប់រហ័សបន្ទាប់ពីដាក់ពាក្យសុំអនុវត្ត។ អានុភាពនៃការរក្សាការពារនឹងកើតមាននៅពេលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីមានដូចជា រដ្ឋបាលសុរិយោដី រាជធានី ខេត្ត។ ការផ្ញើកផ្តាក់នេះ ក្រឡាបញ្ជីត្រូវប្រគល់ឯកសារមួយចំនួនឱ្យទៅស្ថាប័នដែលមានសមត្ថកិច្ច ដើម្បីធ្វើការចុះបញ្ជីមានដូចជា៖ *

- *លិខិតផ្ញើកផ្តាក់ចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ*
- *ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន*

ចំណុចដែលត្រូវសរសេរនៅក្នុងលិខិតផ្ញើកផ្តាក់ឱ្យចុះបញ្ជីមានដូចខាងក្រោម៖

1. អត្តសញ្ញាណនៃអចលនវត្ថុ (លេខក្បាលបញ្ជី ឬ លេខប័ណ្ណ និងទីតាំង)
2. .ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ និងអាសយដ្ឋាន
3. គោលបំណងនៃការចុះបញ្ជី (រឹបអូសជាបណ្តោះអាសន្ន កម្មសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ)
4. មូលហេតុ (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លេខ ចុះថ្ងៃទី ខែ ឆ្នាំ និង ឈ្មោះរបស់តុលាការ)
5. ឈ្មោះម្ចាស់បំណុល និងអាសយដ្ឋាន។
6. ឈ្មោះកូនបំណុល និង អាសយដ្ឋាន។

ក្រោយពីបានចុះបញ្ជីរួចរាល់ហើយ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារសំឡេងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី។ ក្រឡាបញ្ជីត្រូវពិនិត្យ ទៅលើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ហើយអាចស្នើរឲ្យសុរិយោដីធ្វើការកែតម្រូវបាន ប្រសិនបើមានភាពចាំបាច់។ ប៉ុន្តែប្រសិនបើ អចលនវត្ថុដែលត្រូវបានរឹបអូសមិនទាន់បានចុះបញ្ជីទេនោះ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចធ្វើការចុះបញ្ជីអចលនវត្ថុនោះព្រមទាំងការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នផង។

ការរឹបអូសជាបណ្តោះអាសន្ននេះ ពុំត្រូវបានរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ឬ អាស្រ័យផលពីអចលវត្ថុតាមវិធីប្រើធម្មតាឡើយ។ ការប្រើប្រាស់ និងអាស្រ័យផលតាមវិធីប្រើប្រាស់ធម្មតា មានន័យថាជាការប្រើប្រាស់អចលនវត្ថុដោយខ្លួនឯង ឬការទទួលថ្លៃឈ្នួលនៃអចលនវត្ថុ ដែលខ្លួនបានជួលឱ្យគេហើយជាដើម។

យ៉ាងណាមិញ អចលនវត្ថុនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នមិនប្រាកដថា មានតែម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀត បានដាក់ពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុនោះដែរ ចំពោះអចលនវត្ថុដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានសម្រេចរក្សាហើយ ហើយតុលាការទទួលស្គាល់ពាក្យសុំក្រោយតុលាការនេះត្រូវចេញដីកាសម្រេចចាប់ផ្តើមរឹបអូសជាបណ្តោះអាសន្នថ្មីមួយទៀត។ ករណីនេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទង និងដីកាសម្រេចចាប់ផ្តើមមុន។ បើមានភាពច្បាស់លាស់អំពីស្ថានភាពដែលបានបាត់បង់អចលនវត្ថុ ឬស្ថានភាពផ្សេងទៀត ដែលរាំងស្ទះការផ្ទេរអចលនវត្ថុ ដោយការលក់នាពេលអនាគត តុលាការត្រូវអនុវត្តលុបចោលនីតិវិធីរឹបអូសជាបណ្តោះអាសន្ននោះ។

# ជំពូកទី ៣
# ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ

## ៣.១ នីតិវិធីនៃការតវ៉ានូវសេចក្តីសម្រេចចាត់ចែងរក្សាការពារ

ចំពោះដីកាសម្រេចរក្សាការពារ មិនអាចធ្វើការប្តឹងជំទាស់បានភ្លាមៗនោះទេ ប៉ុន្តែចំពោះការមិនសុខចិត្តនឹងដីកាសម្រេចនោះ យើងអាចធ្វើឧបាស្រ័យលើដីកាសម្រេចរក្សាការពារនោះទៅតុលាការ ដែលបានចេញដីកាសម្រេចនោះ។ របៀបនៃឧបាស្រ័យលើដីកា អាចធ្វើការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ អនុលោមទៅតាមផ្នែកទី៤ ស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងការលុបចោលចំពោះដីកាសម្រេចរក្សាការពារ អុនលោមតាមផ្នែកទី៥ ស្តីពី ការលុបចោលដីកាសម្រេចរក្សាការពារនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ ជាឱកាសដែលអាចឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមនីតិវិធីជាមុន ក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃដីកាសម្រេច។ ជាទូទៅ តុលាការធ្វើការចេញដីកាសម្រេចរក្សាការពារដោយផ្អែកលើពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូងរបស់អ្នកដាក់ពាក្យសុំប៉ុណ្ណោះ នោះនាំឱ្យកូនបំណុលមិនអាចធ្វើការឆ្លើយតបបាន ដូច្នេះទើបច្បាប់អនុញ្ញាតឱ្យកូនបំណុលអាចធ្វើការតវ៉ាដីកាសម្រេចរក្សាការពារបាន។

ហេតុនេះ បន្ទាប់ពីតុលាការចេញដីកាសម្រេចរក្សាការពារ កូនបំណុលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចចំពោះដីកាសម្រេចរក្សាការពារ អាចធ្វើការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេច[40] ឬសុំលុបចោលដីកាសម្រេចរក្សាការពារ[41] ទៅតុលាការដែលចេញដីកាសម្រេចនោះ។

### ៣.១.១ ការដាក់ពាក្យសុំតវ៉ា

បន្ទាប់ពីភាគីទទួលបានការបញ្ជូនដីកាសម្រេចរក្សាការពារពីតុលាការ បើយល់ឃើញថា ដីកាសម្រេចរក្សាការពារដែលចេញមកនោះមិនស្របតាមលក្ខខណ្ឌនៃច្បាប់តម្រូវទេ កូនបំណុលអាចសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារ ឬសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារនោះបានតាមរយៈការដាក់ពាក្យសុំនៃភាគី។ ភាគីអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនោះបាន ទៅតុលាការដែលបានចេញដីកាសម្រេចនោះផ្ទាល់។ ពាក្យសុំត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរជាច់ខាត[42] ដើម្បីធានាភាពច្បាស់លាស់។ ចំពោះរយៈពេលនៃការតវ៉ាចំពោះដីកាសម្រេច មិនបានកំណត់អំឡុងពេលជាក់លាក់ណាមួយឡើយ។ ហេតុនេះយើងអាចដាក់ពាក្យសុំបាន ឱ្យតែដីការក្សាការពារនោះនៅមានសុពលភាព។

---

[40] មាត្រា៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[41] មាត្រា៥៥៧ ដល់ ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[42] មាត្រា៥៣៤ ចំនុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ៣.១.២ ការទាញហេតុផលផ្ទាល់មាត់

បន្ទាប់ពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានដាក់រួចរាល់ហើយ ចៅក្រមដែលបានចេញដីកាសម្រេចនោះ ត្រូវធ្វើការកោះហៅភាគី និងធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ តុលាការមិនអាចធ្វើការសម្រេចណាមួយដោយមិនបានឆ្លងកាត់នូវដំណាក់កាលសាកសួរភាគី ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ឡើយ[43]។ ក្រោយពីនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចចេញសេចក្តីសម្រេចណាមួយបាន ហើយនៅក្នុងនីតិវិធីនៃការទាញហេតុផលនេះ ជាសេចក្តីបញ្ជាក់អំពីការបង្ហាញរបស់ភាគីនៅចំពោះមុខតុលាការ។

### ៣.១.៣ ដីកាសម្រេចការសុំតវ៉ាលើដីកាសម្រេចចាត់ចែងរក្សាការពារ

ក្នុងការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេច តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬធ្វើការសាកសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។ នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ដើម្បីឱ្យភាគីមានឱកាសផ្តល់សំអាងបន្ថែមទៀត សម្រាប់ការពារផលប្រយោជន៍របស់ខ្លួន។ ប៉ុន្តែតុលាការអាចធ្វើការប្រកាសភ្លាមបាន អំពីការបញ្ចប់ការវិនិច្ឆ័យនៅកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន[44]។ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរក្សាការពារ។ មានន័យថា ចំពោះដីកាសម្រេចរក្សាការពារចាស់ (ដីកាសម្រេចរក្សាការពារដែលធ្វើពីមុន) ក្នុងករណីដែលយល់ឃើញថាត្រឹមត្រូវ នោះតុលាការត្រូវទទួលស្គាល់ដីកានោះ តែបើមានចំណុចដែលត្រូវកែតម្រូវ ត្រូវធ្វើការផ្លាស់ប្តូរ ហើយបើសិនជាយល់ឃើញថា មិនត្រឹមត្រូវទេតុលាការត្រូវលុបចោល។ ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ដែលធ្វើឡើងតាមការពិចារណារបស់តុលាការនោះ តុលាការអាចដាក់លក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន[45] ។ ចំពោះដីកាសម្រេចការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវបញ្ជូនទៅភាគី ដូចកាលចេញដីកាសម្រេចរក្សាការពារមុនដែរ។

## ៣.២ ការលុបចោលដីកាសម្រេចរក្សាការពារ

[43] មាត្រា៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[44] មាត្រា៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[45] មាត្រា៥៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ៣.២.១ មូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ

ក្នុងករណីដែលដីកាសម្រេចរក្សាការពារត្រូវបានចេញ ហើយមានមូលហេតុមួយចំនួនត្រូវបានកំណត់ដូចមានក្នុង មាត្រា៥៥៧ ដល់មាត្រា៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះ ភាគី ឬកូនបំណុល អាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារនោះបាន។ ដូច្នេះមូលហេតុនៃការសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ រួមមាន៖ ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាអាទិ៍[46]។ ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព[47] ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះ អាសន្នដោយសារស្ថានភាពពិសេស[48]។

- ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាអាទិ៍៖ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល[49] ។ការបង្គាប់នេះហៅថា ការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹងអង្គសេចក្ដី។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឱ្យម្ចាស់បំណុលទទួលលិខិតអនុវត្ត សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះនឹងទប់ស្កាត់ការខូចខាតធ្ងន់ធ្ងរ ដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចរក្សាការពារឱ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹងអាចចេញបាន ដោយមិនតម្រូវឱ្យមានលក្ខខណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ត្រូវមានរយៈពេលតិចជាង ២ (ពីរ) សប្ដាហ៍[50]។ ប្រសិនបើ ម្ចាស់បំណុលមិនបានធ្វើការដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះទេ នៅអំឡុងពេល ដែលបានកំណត់ក្នុងការបង្គាប់ឱ្យដាក់ពាក្យបណ្ដឹងនោះតុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុល។ ក្នុងករណី ដែលក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោលនោះត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ហើយក៏នាំឱ្យចេញដីកាសម្រេចលុបចោលផងដែរ។

---

[46] មាត្រា៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦
[47] មាត្រា៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦
[48] មាត្រា៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦
[49] មាត្រា៥៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦
[50]មាត្រា៥៥៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

- ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព៖ បើមានការរំលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុលបាន ។ ចំពោះការផ្លាស់ប្តូរស្ថានភាពនេះ ត្រូវបានគេបែងចែកចេញជា ២ (ពីរ) ប្រភេទ ។ ប្រភេទទី១ បន្ទាប់ពីចេញដីកាសម្រេចរក្សាការពារ កើតមានឡើងនូវអង្គហេតុថ្មី ដែលអង្គហេតុនោះបានបញ្ជាក់អំពីភាពមិនត្រឹមត្រូវនៃដីកាសម្រេច។ ប្រភេទី២ សំដៅលើកូនបំណុលបានដឹងអំពីអង្គហេតុដែលឆ្លុះបញ្ចាំងអំពីភាពមិនត្រឹមត្រូវនៃដីកាសម្រេចនោះ ឬ អាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីអង្គហេតុនៅក្រោយពេលចេញដីកាសម្រេច ទោះបីជាអង្គហេតុនោះ បានកើតឡើងនៅកំឡុងពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ ដូចច្នេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការផ្លាស់ប្តូរស្ថានភាព។
- ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស៖ ប្រសិនបើ មានការបារម្ភថា ការខូចខាតដែលមិនអាចសងបាននឹងកើតឡើង ដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬមានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តីអាចលុបចោល ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះបានដោយមានល័ក្ខខ័ណ្ឌ តម្រូវឱ្យដាក់ប្រាតិភោគតាមពាក្យសុំរបស់កូនបំណុល[51]។ ករណីដែលអាចលុបចោលដីកាសម្រេចរក្សាការពារ ដោយមានស្ថានភាពពិសេសមានករណីធំ ២(ពីរ) ។

ករណីទី ១ គឺស្ថានភាពដែលអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្ន ដោយការសងជាទឹកប្រាក់ទៅម្ចាស់បំណុល។

ករណីទី២ គឺករណីដែលកូនបំណុលទទួលការខូចខាតមិនធម្មតា ហួសហេតុ តាមទស្សនៈនៃសមភាពរវាងភាគីទាំងសងខាង[52]។ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ចំពោះករណីស្ថានភាពពិសេសដូចមានកំណត់ខាងលើ។ គ្រប់បទប្បញ្ញត្តិនៃមូលហេតុដែលនាំឱ្យមាន ការលុបចោលដីកាសម្រេចរក្សាការពារត្រូវបានយកមកអនុវត្តដូចគ្នានៃបញ្ញត្តិ មាត្រា៥៤៣ ស្តីពីការបញ្ជូនរបស់តុលាការចំពោះដីកាសម្រេចការពារ ក្នុងគោលបំណងឱ្យភាគីបានដឹងច្បាស់អំពីខ្លឹមសារនៃដីកាសម្រេច និងបន្សល់ឱ្យភាគីនូវមធ្យោបាយបញ្ជាក់។

[51] មាត្រា៥៥៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

[52] មាត្រា៥៥៨ នៃសេចក្តីកំណត់ចំពោះមាត្រា នីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.២.២ ការទាញហេតុផលផ្ទាល់មាត់

នីតិវិធីនៃសំណុំរឿងរក្សាការពារ ក្នុងសំណុំរឿងរដ្ឋប្បវេណី តុលាការមិនអាចចេញដីកាសម្រេចណាមួយបានឡើយ បើមិនបានឆ្លងកាត់នូវនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីម្ចាស់បំណុល និងភាគីកូនបំណុលអាចចូលរួមបាន។ ដូច្នេះនៅក្នុងផ្នែកនៃការលុបចោល ដីកាសម្រេចរក្សាការពារ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបញ្ញត្តិ មាត្រា៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ៣.២.៣ ផ្អាកបណ្តោះអាសន្ន

បញ្ញត្តិពី មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និងមាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការសម្រេចសេចក្តី អំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌ១ មាត្រា៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍) ។ ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារជាអាទិ៍) នៃនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវយកមកអនុវត្តដូចគ្នា ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តីផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៥៥១ នោះបានដែរ [53]។

ជារួមនៅពេល ដែលមានពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារតុលាការអាចបង្គាប់ឱ្យផ្អាកលើការអនុវត្ត ឬលុបចោលនូវការចាត់ចែងការអនុវត្តតាមពាក្យសុំ ដោយភ្ជាប់ជាមួយនឹងការដាក់ប្រាតិភោគបានរហូតដល់ធ្វើការសម្រេច អំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារក្នុងស្ថានភាពពិចារណាថា តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចជាមុនសិន។ មានន័យថា ការអនុវត្តការរក្សាការពារមិនអាចផ្អាកបានឡើយ បើត្រឹមតែធ្វើការតវ៉ាចំពោះដីកាសម្រេចរក្សាការពារនោះ ស្ថានភាពដែលច្បាស់ថា ជាមូលហេតុ នៃការលុបចោលដីកាសម្រេចរក្សាការពារ និងការដែលបារម្ភថា មានការខូចខាតដែលមិនអាចធ្វើការសងបាននឹងកើតឡើងដោយការអនុវត្តរក្សាការពារ ហើយចាំបាច់ត្រូវដាក់ប្រាតិភោគ ទើបអាចធ្វើការផ្អាកការអនុវត្តរក្សាការពារបានដោយការតវ៉ាចំពោះដីកាសម្រេច ដែលត្រូវបំពេញល័ក្ខខ័ណ្ឌខាងលើនេះ។

[53] មាត្រា៥៦០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ៣.២.៤ អានុភាពនៃដីកាដែលសម្រេចលុបចោលដីកាសម្រេច

ដីកាសម្រេចអំពីពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារ និងដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ មិនមានអានុភាពឡើយ ក្នុងករណីដែលមិនទាន់ចូលជាស្ថាពរ។ ប៉ុន្តែបើយល់ឃើញថា ចាំបាច់ករណីពិសេសតុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ។ ជាគោលការណ៍ ដីកាសម្រេចមានអានុភាពនៅពេលជូនដំណឹង[54]។ ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរមានន័យថា ដីកាសម្រេចរក្សាការពារនៅតែមានអានុភាពដដែល។

## ៣.៣ ការបណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ ឬ អាចនិយាយម្យ៉ាងទៀតបានថា បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចដែលតុលាការចេញក្នុងរឿងក្តីការចាត់ចែងរក្សាការពារចំពោះករណីមួយចំនួនដែលច្បាប់បានចែងទុកជាមុន។

### ៣.៣.១ មូលហេតុនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់អាចធ្វើទៅបានអាស្រ័យដោយមូលហេតុដូចខាងក្រោម៖ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ[55] ។ ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ។ នីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានរយៈពេលយូរ ឬយឺតជាងការតវ៉ា ហើយការតវ៉ាគ្រាន់តែជានីតិវិធីបន្ថែមលើបណ្តឹងជំទាស់តែប៉ុណ្ណោះ។ ហើយបណ្តឹងជំទាស់ ត្រូវបានយកមកអនុវត្តដូចគ្នាចំពោះបញ្ញត្តិមួយចំនួនផងដែរទៅនឹងនីតិវិធីនៃការតវ៉ា។

### ៣.៣.២ ការទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងបណ្តឹងជំទាស់ ជាបណ្តឹងឧបាប្រាស័យរបស់ភាគី ដែលធ្វើបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់តុលាការ ដែលសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ឬ លើកពាក្យសុំរបស់ម្ចាស់បំណុលជាដើម ដូចដែលបានពន្យល់ក្នុងមូលហេតុនៃបណ្តឹងជំទាស់។ នៅពេលដែល ម្ចាស់បំណុល ឬកូនបំណុល ធ្វើបណ្តឹងជំទាស់តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលស្របតាម មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការមិនអាចធ្វើការវិនិច្ឆ័យសេចក្តីបានទេ បើគ្មានការឆ្លងកាត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

[54] មាត្រា២១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ០៦ កក្កដា ២០០៦

### ៣.៣.៣ ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្ដឹងជំទាស់

ការបញ្ចប់ការវិនិច្ឆ័យនៅក្នុងបណ្ដឹងជំទាស់ វាក៏មិនខុសគ្នាពី ការវិនិច្ឆ័យនៃការតវ៉ាដែរ។ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដោយសមរម្យ។ ប៉ុន្តែបើតុលាការ បានកំណត់កាលបរិច្ឆេទការវិនិច្ឆ័យហើយ តុលាការអាចប្រកាសភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យដូចដែលបានកំណត់ទៅតាមកាលបរិច្ឆេទ។

### ៣.៣.៤ អំឡុងពេលនៃបណ្ដឹងជំទាស់

រាល់ការចេញដីកាសម្រេចរក្សាការពារដែលបានរៀបរាប់ខាងលើរួមមាន ការប្ដឹងតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬពាក្យសុំទាមទារលុបចោលដីការក្សាការពារ ឬការធ្វើបដិទានរបស់ម្ចាស់បំណុលជាអាទិ៍ ត្រូវបានកំណត់រយៈពេលក្នុងការប្ដឹងជំទាស់គឺមានអំឡុងពេល ២ (ពីរ)សប្ដាហ៍ចាប់ពីថ្ងៃ ដែលបញ្ជូនដីកាសម្រេចនេះទៅដល់អ្នកដែលមានសិទ្ធិក្នុងការធ្វើបណ្ដឹងជំទាស់ៗ ហើយរយៈពេលដែលបានកំណត់ខាងលើនេះមិនអាចពន្យារបានឡើយ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ នូវសារណាបញ្ចប់ការសិក្សាលើប្រធានបទ ការចាត់ចែងរក្សាការពារលើអចលនវត្ថុរួចមក ខ្ញុំបាទ/នាងខ្ញុំ អាចសន្និដ្ឋានបានថា ប្រធានបទនេះគឺជានីតិវិធីមួយដែលល្អមានលក្ខណៈជាបណ្តោះអាសន្នក្នុងគោលបំណងការពារនូវផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល នៅមានការព្រួយបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬការសម្រេចនូវសិទ្ធក្នុងការទាមទារត្រូវបានរាំងស្ទះដោយសារតែការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ចំពោះចំនុចនេះយើងអាចនិយាយម្យ៉ាងទៀតថា ដើម្បីធានាថែរក្សាទ្រព្យសម្បត្តិរបស់កូនបំណុលឱ្យនៅដដែល មិនឱ្យកូនបំណុលធ្វើការផ្ទេរកម្មសិទ្ធបាន ដើម្បីធានាដល់សិទ្ធនៃការទាមទាររបស់ម្ចាស់បំណុល នៅក្នុងករណីដែលមានការខូចខាតធ្ងន់ធ្ងរ ដោយសារមានវិវាទទាក់ទងនិងសិទ្ធទើបមានការរក្សាការពារជាបណ្តោះអាសន្នលើវិវាទ ដើម្បីទទួលបានសំណងជាបណ្តោះអាសន្ន ។ ចំពោះចំនុចដែលខ្ញុំលើកឡើងខាងលើនេះ ជាគុណសម្បត្តិនៃការចាត់ចែងរក្សាការពារ។ ម្ចាស់បំណុលត្រូវដាក់ពាក្យស្នើសុំមកតុលាការ ដើម្បីចេញដីកាសម្រេចរក្សាការពារ តុលាការ និងពិនិត្យលើពាក្យសុំនោះថា មានភាពត្រឹមត្រូវ និងមានអំណះអំណាងរបស់ម្ចាស់បំណុលច្បាស់លាស់ឬទេ ដើម្បីតុលាការអាចធ្វើការចាត់ចែងរក្សាការពារ ឬលើកចោលនូវពាក្យសុំនោះ ។ នៅពេលតុលាការចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវតែដាក់ពាក្រសុំអនុវត្តដីការក្សាការពារ ដើម្បីយកដីកានោះទៅអនុវត្ត ។ បើសិនជាមានភាគីណាមួយ មិនសុខចិត្តចំពោះដីការក្សាការពារ អាចធ្វើបណ្តឹងជំទាស់ ឬពាក្យសុំតវ៉ាបាន ។ នីតិវិធីនេះ ពិតជាមានមានអត្ថប្រយោជន៍ក្នុងការ ការពារសិទ្ធ និងផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុលពិតប្រាកដមែន ដោយសារតែមិនចាំបាច់រង់ចាំសាលក្រម ឬសាលដីកាចូលជាស្ថាពរនោះទេ ។ ភាពរហ័ស និងសម្ងាត់នៃនីតិវិធីនេះ អាចកាត់បន្ថយនូវក្តីបារម្ភរបស់ម្ចាស់បំណុល។ វាមានគុណវិបត្តិខ្លះផងដែរដូចជា នៅពេលដែលអនុវត្តការរក្សាការពារ វាធ្វើឱ្យខូចខាតដោយសារអានុភាពនៃ ការផ្អាក ឬការហាមឃាត់ របស់ដីកាសម្រេចរក្សាការពារផងដែរ ព្រោះតែកំហុសមិនបានឱ្យភាគីធ្វើការដាក់ប្រាតិភោគចំពោះដីកាសម្រេចនោះ ។ មួយវិញទៀត នៅពេលដែលអដ្ឋាសាលា ឬសមត្ថកិច្ចចុះទៅអនុវត្តដីកាសម្រេចរក្សាការពារ វាមានការលំបាក ដោយសារតែអ្នកកាន់កាប់នូវអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរក្សាការពារនោះអាចតបត ឬប្រឆាំងបាន ដូចនេះ ទាល់តែមានជំនួយពីនគរបាល ឬកងរាជអាវុធហត្ថ ដើម្បីបង្ការ ឬលុបបំបាត់នូវការប្រឆាំងតបតបាន ។

សរុបសេក្តីមក ការចាត់ចែងរក្សាការពារនេះ មានលក្ខណៈជាបណ្តោះអាសន្ន និងមានភាពឆាប់រហ័សដោយពុំចាំបាច់រង់ចាំរហូតដល់ចេញ សាលក្រម ឬ សាលដីកាស្ថាពរក្នុងគោលដៅដើម្បីការពារសិទ្ធ និងផល

ប្រយោជន៏ស្របច្បាប់របស់បុគ្គលទូទៅ ដែលជាភាគីនៃវិវាទអាចទទួលបាននូវការខាតបង់ ដែលអាចនឹងកើតឡើងជាក់ជាពុំខានប្រសិនបើមិនទប់ស្កាត់ឱ្យទាន់ពេលវេលា ។

# អនុសាសន៍

បន្ទាប់ពីបានសិក្សាអំពីប្រធានបទ ការចាត់ចែងរក្សាការពារលើអចលនវត្ថុរួចមក យើងខ្ញុំយល់ឃើញថា ការចាត់ចែងរក្សាការពារលើអចលនវត្ថុនេះពិតជាមានភាពលំបាកខ្លះៗ ក្នុងការស្វែងយល់ ។ ដូចច្នេះហើយតម្រូវឱ្យអ្នកស្រាវជ្រាវ អ្នកសិក្សាច្បាប់ សិស្ស និស្សិត សាធារណៈជនគ្រប់មជ្ឈដ្ឋាន និងអ្នកអនុវត្តច្បាប់ទាំងអស់ធ្វើយ៉ាងណាសិក្សាស្វែងយល់អំពីនីតិវិធីនេះឱ្យបានស៊ីជម្រៅ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ។

មួយវិញទៀតយើងខ្ញុំយល់ឃើញថាប្រជាពលរដ្ឋមួយចំនួនធំនៅមិនទាន់មានការយល់ដឹងទូលំទូលាយអំពីនីតិវិធីចាត់ចែងរក្សាការពារលើអចលនវត្ថុនៅឡើយ ទោះបីមានក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដែលបានប្រកាសឱ្យប្រើអស់រយៈពេលជាង១០ឆ្នាំក៏ដោយ ។

ជាអនុសាសន៍៖

- ក្រសួងយុត្តិធម៌គួរតែបង្កើតសិក្ខាសាលា ឬបទបង្ហាញឱ្យបានច្រើនទៅនឹងផ្នែកច្បាប់ ដើម្បីឱ្យអ្នកសិក្សាស្រាវជ្រាវច្បាប់គ្រប់មជ្ឈដ្ឋានបានសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ
- បង្កើត និងបង្កើនការចាក់ផ្សាយកម្មវិធីសម្ភាសជាមួយអ្នកច្បាប់
- ត្រូវពង្រីកការផ្សព្វផ្សាយបន្ថែម អំពីនីតិវិធីនានា ក្នុងរឿងក្ដីរដ្ឋប្បវេណី
- បង្កើតកម្មវិធីសំណួរចម្លើយទាក់ទង និងផ្នែកច្បាប់ឱ្យបានច្រើន
- ធ្វើបច្ចុប្បន្នភាពទៅលើកម្មវិធីដែលផ្សព្វផ្សាយទាក់ទង និងច្បាប់ឱ្យមានភាពនវានុវត្តន៍ ។

# ឯកសារយោង

**១. បទដ្ឋានគតិយុត្ត៖**

- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៧០៦/០២១, ២៦ ខែឧសភា ឆ្នាំ ២០០៦
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

**២. ឯកសាររបស់អ្នកស្រាវជ្រាវ៖**

- សេចក្តីកំណត់មាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ២ ៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយ ក្រុមការងារ ជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩
- សៀវភៅមេរៀនកិច្ចការក្រឡាបញ្ជី ឆ្នាំ ២០០៦

**៣. គេហទំព័រ៖**

- គេហទំព័រ សារពត៌មាន ThmeyThmey៖ https://thmeythmey.com/
- គេហទំព័រ សារពត៌មាន Fresh News៖ http://www.freshnewsasia.com/

# ឧបសម្ព័ន្ធ

# គំរូពាក្យសុំចេញដីកាការក្សាការពារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៧

**ពាក្យសុំដីកាសម្រេចរក្សាការពារ**

ខ្ញុំបាទឈ្មោះ មាស ពេជ្រ ជាមេធាវី អ្នកតំណាងដោយអាណត្តិ របស់លោក ខៀវ អាត ដូចដែលមានបញ្ជាក់ក្នុងបញ្ជីភាគី ដែលមាននៅក្នុងឯកសារឧបសម្ពន្ធ ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងក្រុងភ្នំពេញ**

**កម្មវត្ថុៈ ពាក្យសុំដីកាសំរេចរឹបអូសជាបណ្តោះអាសន្ន**

ខ្ញុំបាទឈ្មោះ ខៀវ អាត សុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដូចដែលមានបញ្ជាក់នៅក្នុងបញ្ជីអចលនវត្ថុនៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធរបស់កូនបំណុលឈ្មោះ សុខ បូរ៉ា ដូចដែលមានបញ្ជាក់ក្នុងបញ្ជីភាគីនៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ ដើម្បីធានានូវការអនុវត្តសិទ្ធិលើបំណុលរបស់ខ្ញុំបាទចំពោះកូនបំណុលដូចមាននៅក្នុងឯកសារឧបសម្ព័ន្ធស្តីពី បញ្ជីសិទ្ធិលើបំណុល ។

**មូលដ្ឋាននៃពាក្យសុំ**

**១_សិទ្ធិដែលត្រូវបានរក្សាការពារ :**

ម្ចាស់បំណុលឈ្មោះ ខៀវ អាត បានឱ្យកូនបំណុលឈ្មោះ សុខ បូរ៉ា ខ្ចីប្រាក់ចំនួន ៨.០០០ ដុល្លា ដោយ មានការព្រមព្រៀងសងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៤ ប៉ុន្តែកូនបំណុលមិនបានសងប្រាក់ទៅម្ចាស់បំណុលទេ ទោះបីកាលបរិច្ឆេទនៃការកំណត់សងថ្ងៃទី០១ ខែមថុនា ឆ្នាំ២០០៦ បានកន្លងហួសទៅហើយក៏ដោយ ។ ប្រហែលនៅខែកក្កដា ឆ្នាំ២០០៦ ម្ចាស់បំណុលបានដាស់តឿនជាញឹកញាប់ ប៉ុន្តែកូនបំណុលមិនបានសងប្រាក់ឡើយ ។

**២_ភាពចាំបាច់សម្រាប់នៃការរក្សាការពារ:**

កូនបំណុលបានអះអាងថា គាត់បានសងប្រាក់ចំនួន ៦.០០០ដូល្លារ មុនកាលកំណត់សង ហើយបំណុលដែលនៅសល់ម្ចាស់បំណុលបានលើកលែងទៅវិញ ។

-កូនបំណុលបានជំពាក់ប្រាក់ញាតិសណ្តានច្រើនណាស់ ដោយកូនបំណុលយកប្រាក់នោះទៅចំណាយលើថ្លៃព្យាបាលឪពុករបស់គាត់ ហើយគាត់ស្ថិតនៅក្រោមសំពាធត្រូវសងប្រាក់កំចីទៀត។ បន្ថែមលើនេះ ការរកស៊ីរបស់កូនបំណុល មើលទៅមិនដំណើរការល្អសោះ។ កូនបំណុលជាម្ចាស់នៃអាគារ និងដីមួយកន្លែង (A២)ប៉ុន្តែគ្មានទ្រព្យពិសេសផ្សេង ទៀតក្រៅពីនេះទេ។ បន្ថែមលើបំណុលក្នុងរឿងក្តីបច្ចុប្បន្ន ហើយស្ថិតក្នុងស្ថានភាពមួយដែលកូនបំណុលអាចចាត់ចែង ទ្រព្យរបស់ខ្លួនគ្រប់ពេល ដូចមានការបង្ហាញក្នុងបញ្ជីអំពីអចលនវត្ថុ (A៣) ។

-មានតែទ្រព្យនីមួយៗដែលបានរៀបរាប់នៅក្នុងឯកសារពិពណ៌នាអំពីអចលនវត្ថុ ត្រូវបានរឹបអូសជាបណ្តោះអាសន្នជាមុនទេ ទើបម្ចាស់បំណុលអាចអនុវត្តសិទ្ធិបាន បើមិនដូច្នោះទេ ម្ចាស់បំណុលមិនអាច ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសាលក្រមនៅពេលដែលម្ចាស់បំណុលឈ្នះក្តី ។

**ឯកសារបញ្ជាក់ដំបូង**

A១ : លិខិតកិច្ចសន្យាខ្ចីបរិភោគ

A២ : លិខិតយថាភូតនៃការចុះបញ្ជីអចលនវត្ថុ

A៣ : របាយការណ៍រៀបចំដោយម្ចាស់បំណុល

**ឯកសារភ្ជាប់**

| | |
|---|---|
| ភស្តុតាង A១. A២. និងA៣ | ១ច្បាប់សម្រាប់ភស្តុតាងនីមួយៗ (ថតចម្លង) |
| លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ១ច្បាប់ (ថតចម្លង) |

**ហត្ថលេខា**

**មាស ពេជ្រ**

## គំរូដីកាសម្រេចរក្សាការពារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### សាលាដំបូងខេត្តកំពង់ឆ្នាំង

ដីកាសម្រេចលេខ: ៨១ (ក)

## ដីកាសម្រេចរក្សាការពារ

ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

យើង **គឹម រ័ត្នណារិន** ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

-បានឃើញ: ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញ: សំណុំរឿងរក្សាការពារលេខ **៤៣** ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១។

-បានឃើញ: ពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ។

រវាងសហម្ចាស់បំណុល:

១-ឈ្មោះ **សាត សុភ័ក្រ** ភេទប្រុស កើតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៨០ ជនជាតិខ្មែរ របររកស៊ីអាជីវករ មានអាសយដ្ឋានបច្ចុប្បន្នភូមិពាមលង្វែក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ប្រពន្ធឈ្មោះ លី ភក្រា មានកូន ០២នាក់ ។

**២**-ឈ្មោះ **សាត សុផល** ភេទស្រី កើតនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨២ ជនជាតិខ្មែរ របររកស៊ីអាជីវករ មានអាសយដ្ឋានបច្ចុប្បន្នភូមិពាមលង្វែក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល មានប្ដីឈ្មោះ កែម ស៊ីណា (លែងលះ) គ្មានកូន ។

និងកូនបំណុលឈ្មោះ **ប៊ុត បុត្រា** ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មានអសយដ្ឋានផ្ទះលេខ: ០៤២ ផ្លូវលេខ៥៩៨ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុ</u>** សុំតុលាការចេញដីការក្សាការពារហាមឃាត់កូនបំណុលមិនឱ្យធ្វើសកម្មភាព ឈូសឆាយ សាងសង់ ជីកកកាយ កាប់គាស់ ដាំដំណាំ លក់ដូរ ធ្វើបណ្ដាំមរតក ធ្វើអំណោយទាន វិភាគទាន សាងសង់

សំណង់ផ្សេងៗ និង ចុះបញ្ជីដី ទៅឱ្យអ្នកដទៃទៀត លើដីពីរកន្លែង គឺដីទី១ មានទំហំ០៥ហិចតា ស្ថិតនៅភូមិ កំពង់ត្រឡាច ក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងទី២ មានទំហំ០៣ ហិចតា ស្ថិតនៅភូមិត្រពាំងភ្លៅ ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទុកជាបណ្តោះអាសន្ន ។

-បានឃើញ លិខិតស្នើសុំបញ្ជាក់ដី ចុះថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០២០ ។

-បានឃើញ កិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ។

-បានឃើញ លិខិតស្នើសុំបញ្ជាក់ដី ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ។

## សំអាងហេតុ

-ពាក្យសុំចេញដីការក្សាការពារចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២១ របស់ម្ចាស់បំណុលឈ្មោះ សាត សុភ័ក្រ និងឈ្មោះ សាត សុផល មានលក្ខណៈត្រឹមត្រូវតាមមាត្រា ៥៣៤ និង មាត្រា ៥៤០ និង មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល ឈ្មោះ សាត សុភ័ក្រ និង ឈ្មោះ សាត សុផល បានថ្លែងថាខ្លួនសុំឱ្យតុលាការចេញដីការក្សាការពារដូចមាននៅក្នុងពាក្យសុំចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ លើដីទាំងពីរកន្លែងដែលមានទំហំ និង ទីតាំងដូចតទៅ:

១-ដីចំការ៥១២៧២ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ ភារុន ខាងលិចទល់នឹងផ្លូវ និង ខាងជើងទល់នឹងយាយ ភួន។

២-ដីចំការទីតាំងស្ថិតនៅភូមិត្រពាំងភ្លៅ ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មាន:

ក-ទំហំ ១៤៨៣១ម៉ែត្រការ៉េ មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ ស៊ីម សុផល ,ខាងលិចទល់នឹងដីចំណីផ្លូវ ,ខាងត្បូងទល់នឹងដីចំណីផ្លូវ និងខាងជើងទល់នឹងឈ្មោះ ឃួន សុខុម ។

ខ-ទំហំ ១៥៦៧៨ម៉ែត្រការ៉េ មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ ចិន សុភាព ,ខាងលិចទល់នឹងផ្លូវរទេះ ខាងជើងទល់នឹងផ្លូវរទេះ និង ខាងត្បូងទល់នឹង ឈ្មោះ អ៊ុំ អឿន ។

ខ្លួនសុំរក្សាការពារហាមឃាត់ឈ្មោះ ប៊ុត បុត្រា មិនឱ្យធ្វើសកម្មភាពនានាដូចជា មិនឱ្យធ្វើសកម្មភាពឈូសឆាយ ជីកស្រះ ជីកកកាយដី សាងសង់សំណង់នានា ដាំដំណាំ លក់ ដូរ ជួល បញ្ចាំ ធ្វើបណ្តាំមរតក ធ្វើអំណោយទាន វិភាគទាន ផ្ទេរកម្មសិទ្ធិ ប្រទានកម្ម និង ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឱ្យអ្នកដទៃ ។

មូលហេតុដែលខ្លួនសុំរក្សាការពារខាងលើដោយសារថា រវាងខ្លួន និង ឈ្មោះ ប៊ុត បុត្រា បានស្គាល់គ្នាយូរហើយ ធ្លាប់រកស៊ីជាមួយគ្នា ក្នុងការទិញលក់ដី ហើយនៅកំឡុងខែមិថុនា ឆ្នាំ២០២០ ឈ្មោះ ប៊ុត បុត្រា បានឱ្យ ខ្លួនទាំងពីរនាក់បងប្អូនទៅខ្ចីប្រាក់អ្នកភូមិចំនួន ៧ ០០០ ដុល្លារអាមេរិក ដើម្បីយកមករត់ការដីពីរប្លង់ ខាងលើ ដែលទិញពីគេ ដោយឈ្មោះ ប៊ុត បុត្រា សន្យាថា ពេលបានដីនេះមកគាត់ជាម្ចាស់ហើយ គាត់នឹង សងប្រាក់ដើម និង ការប្រាក់មកឱ្យខ្លួនយកទៅឱ្យម្ចាស់បំណុលវិញ តែចាប់តាំងពីបានដីជារបស់គាត់ៗមិនបានយកប្រាក់ និង ការប្រាក់មកឱ្យខ្លួនយកទៅសងគេឡើយរហូតមកដល់បច្ចុប្បន្ននេះ ។ ខ្លួនសូមបញ្ជាក់ថា ប្រាក់ដែលខ្លួន ខ្ចីឯកជន ក្នុងចំនួន ១០០ ដុល្លាអាមេរិក គេយកការចំនួន ២០ដុល្លាររអាមេរិក ក្នុងមួយខែ បើគិតចាប់តាំងពីខែមិថុនា ២០២០ រហូតមកដល់ពេលដាក់ពាក្យសុំដីការក្សាការពារ គឺបើកគិតជាការប្រាក់ចំនួន ១៦ ៨០០ដុល្លាររអាមេរិច ហើយ ហេតុនេះ ប្រាក់ដើម និង ការប្រាក់ខ្លួនត្រូវទាមទារយកគ្រប់ចំនួនវិញ ។

ម្យ៉ាងទៀតខ្លួនសុំដីការរក្សាការពារីបអូសជាបណ្ដោះអាសន្នខាងលើ ដោយសារកូនបំណុល បាន កំពុងរៀបចំ ចាត់ចែងដីខាងលើ ដោយពុំមានបំណងសងប្រាក់មកខ្លួនឡើយ ។

-មូលហេតុដែលម្ចាស់បំណុលដាក់ពាក្យសុំដីការសម្រេចរក្សាការពារព្រោះកូនបំណុលឈ្មោះ ប៊ុត បុត្រា បាន ឱ្យម្ចាស់បំណុលទៅខ្ចីចងការប្រាក់ដើម្បីយកមកចំណាយលើដីចំការ ទំហំ ៥១ ២៧២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ ខាងកើតទល់នឹង ប្រឡាយ ,ខាងត្បូងទល់នឹងឈ្មោះ ភារុន ,ខាងលិចទល់នឹងផ្លូវ និង ខាងជើងទល់នឹងយាយភួន និងដីចំការ(ទំហំ ១៤៨៣១ម៉ែត្រការ៉េ មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ ស៊ីម សុផល .ខាងលិចទល់នឹងដី ចំណីផ្លូវ ,ខាងត្បូងទល់នឹងដីចំណីផ្លូវ និង ខាងជើងទល់ឈ្មោះ ឃួន សុខុម និងទំហំ ១៥៦៧៨ម៉ែត្រការ៉េ មានព្រំ ប្រទល់ខាងកើតទល់ នឹងឈ្មោះ ចិន សុភាព .ខាងលិចទល់នឹងផ្លូវរទេះ ខាងជើង ទល់នឹងផ្លូវរទេះ និង ខាងត្បូង ទល់នឹងឈ្មោះ អ៊ុំ អឿន ទីតាំងស្ថិតនៅភូមិត្រពាំងភ្នៅ ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ហើយប្រាក់ នេះ កូនបំណុលមិនទាន់បាន ទូទាត់សងទៅឱ្យម្ចាស់បំណុលនៅឡើយ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផល ប្រយោជន៍របស់ម្ចាស់បំណុល ទើបម្ចាស់ បំណុលដាក់ពាក្យសុំដីកាសម្រេចរក្សាការពារមកតុលាការ ។

-តាមកិច្ចសន្យាលក់ផ្ដាច់ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ យូ សុះសាឡេះ .ឈ្មោះ ទិត្យ លី និង កិច្ចសន្យាលក់ផ្ដាច់ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ អ៊ុំ អឿន ឈ្មោះ កែវ ឡី និង ឈ្មោះ ឃួន ខុម បាន លក់ដីទៅឱ្យឈ្មោះ ប៊ុត បុត្រា និង តាមលិខិតបញ្ជាក់ពីការបង់ពន្ធលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលន

ទ្រព្យ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២០ បង្ហាញឱ្យឃើញថា ម្ចាស់ដីបានផ្ទេរកម្មសិទ្ធិដីទៅ ឱ្យឈ្មោះ ប៊ុត បុត្រា រួចរាល់ហើយ នៅឡើយតែឈ្មោះ ប៊ុត បុត្រា មិនទាន់អនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសងប្រាក់ទៅឱ្យឈ្មោះ សាត សុភ័ក្រ និង ឈ្មោះ សាត សុផល តែប៉ុណ្ណោះ ហេតុនេះម្ចាស់បំណុលស្នើសុំឱ្យ តុលាការហាមឃាត់ជាបណ្តោះអាសន្ន ដើម្បីជៀសវាងកូនបំណុលធ្វើសកម្មភាពនានាមានដូចជា លក់ ដូរ ជួល បញ្ចាំ ធ្វើ បណ្តាំមរតក តុលាការអាចពិចារណាបាន ដោយហេតុថា ការសុំរក្សាការពារនេះ គឺដើម្បីការពារកុំឱ្យកូនបំណុលធ្វើការចាត់ចែងទ្រព្យសម្បត្តិ ដែលអាចធានាដល់ការអនុវត្តដោយបង្ខំ ។

-ការទាមទាររបស់ម្ចាស់បំណុលមានមូលហេតុសមរម្យ និងចាត់ទុកថា ជាស្ថានភាពបន្ទាន់មួយ ដើម្បីការពារ និងធានារក្សានូវស្ថានភាពបច្ចុប្បន្ន នៃអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនេះ ដោយហេតុថា ម្ចាស់បំណុល មានការបារម្ភថានឹងមិនអាចអនុវត្តសិទ្ធ ឬមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃអចលនវត្ថុនេះ ដូច្នេះបើគ្មានវិធានការការពារនោះទេកូនបំណុលនឹងអាចធ្វើការ លក់ ដូរ ជួល បញ្ចាំ ធ្វើ បណ្តាំមរតក វិភាគទាន ចុះបញ្ជីដី ដែលអាចឱ្យមានការប្រែប្រួលស្ថានភាពជាក់ស្តែងលើអចលនវត្ថុខាងលើ ដែលទង្វើនេះប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់ របស់ម្ចាស់បំណុលនាពេលអនាគត។

-ដើម្បីជៀសវាងដល់ផលវិបាកផ្សេងៗដែលអាចកើតមានជាយថាហេតុ ការរឹបអូសសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុល គឺមានភាពចាំបាច់ ដើម្បីធានាសិទ្ធិលើបំណុល និង ធានាដល់ការអនុវត្តនាពេលក្រោយ និងដើម្បីជៀសវាងនូវផលវិបាកផ្សេងៗ ប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុល តុលាការគប្បីពិចារណាចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបាន ដោយរង់ចាំសេចក្តីសម្រេចអំពីបណ្តឹងអង្គសេចក្តីស្របតាមមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយហេតុថាការស្នើសុំរឹបអូសនេះ គ្រាន់តែជាវិធានការណ៍ បណ្តោះអាសន្នប៉ុណ្ណោះ មិនមានប៉ះពាល់ដល់អង្គសេចក្តីឡើយ ។

-ការស្នើសុំរបស់ម្ចាស់បំណុលហាមឃាត់មិនឱ្យឈូសឆាយ សាងសង់ ជីកកកាយ កាប់គាស់ ដាំដំណាំនូវអចលនវត្ថុ តុលាការយល់ឃើញថា ការស្នើសុំរបស់ម្ចាស់បំណុល អាចនាំឱ្យមានការប៉ះពាល់ដល់ការប្រកបមុខរបរ និងជីវភាពប្រចាំថ្ងៃរបស់កូនបំណុល ក៏ដូចជានាំឱ្យមានការប៉ះពាល់ដល់បណ្តឹងអង្គសេចក្តី ហេតុដូច្នេះ តុលាការ មិនលើកយកមកពិចារណា និង សម្រេចតាមការស្នើសុំរបស់កូនបំណុលបានទេ ។

-ប្រាក់ប្រដាប់ក្តី គប្បីជាបន្ទុករបស់ម្ចាស់បំណុលតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១-រឹបអូសជាបណ្តោះអាសន្នដោយហាមឃាត់កូនបំណុលឈ្មោះ ប៊ុត បុត្រា លក់ ដូរ ជួលបញ្ចាំ ធ្វើបណ្តាំ មរតក អំណោយទាន និង ចុះបញ្ជីដី ទៅឱ្យអ្នកដទៃទៀត នូវអចលនវត្ថុរួមមាន ៖

ក-ដីចំការទំហំ ៥១២៧២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ ភារុន ខាងលិចទល់នឹងផ្លូវ និង ខាងជើងទល់នឹងយាយ ភួន។

ខ-ដីចំការទំហំ ១៤៨៣១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងភ្នៅ ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ ស៊ឹម សុផល ខាងលិចទល់និងដីចំណីផ្លូវ ខាងត្បូងទល់នឹងដីចំណីផ្លូវ និងខាងជើងទល់ឈ្មោះ ឃួន សុខុម ។

គ-ដីចំការទំហំ ១៥៦៧៨ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងភ្នៅ ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានព្រំប្រទល់ខាងកើតទល់ឈ្មោះ ចិន សុភាព ខាងលិចទល់និងផ្លូវរទេះ ខាងជើងទល់នឹងផ្លូវរទេះ និងខាងត្បូងទល់នឹងឈ្មោះ អ៊ុំ អឿន ។

២-ដីកានេះមានអនុភាពអនុវត្តភ្លាមៗ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលម្ចាស់បំណុលបានបង់ទុករួចហើយ។

ទុកសិទ្ធឱ្យកូនបំណុលប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។